លេខាធិការដ្ឋាន គ.ជ.អ.ប

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ប្លង់មេរៀនស្តីពី

## ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ របស់ ឃុំ សង្កាត់



ឆ្នាំ ២០១៥

# សេចក្តីផ្តើម និង ការរំពឹងទុក

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖<br>▪ រៀបរាប់បានអំពីគោលដៅ គោលបំណង និងកាលវិភាគរបស់វគ្គបណ្តុះបណ្តាល<br>▪ បញ្ជាក់គោលការណ៍ នីតិវិធី និងឧបករណ៍ សម្រាប់ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ |
| **ខ្លឹមសារសំខាន់** | ▪ គោលដៅ គោលបំណង និងកាលវិភាគរបស់វគ្គ<br>▪ គោលការណ៍សម្រាប់អនុវត្តន៍ក្នុងវគ្គបណ្តុះបណ្តាល |
| **រយៈពេល** | ▪ ៩០ នាទី |
| **សំភារៈ** | <br>▪ គោលដៅ គោលបំណង និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល<br>▪ បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុនវគ្គបណ្តុះបណ្តាល |
| **វិធីសាស្ត្រ** | ▪ លំហាត់ និងបទបង្ហាញ |



## សកម្មភាពសម្របសម្រួលមេរៀន

| (ពេលវេលា) | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្តីផ្តើម និងគោលបំណងមេរៀន**<br>មុនចាប់ផ្តើមវគ្គ៖<br>▪ អ្នកសម្របសម្រួលណែនាំខ្លួន ព្រមទាំងស្វាគមន៍សិក្ខាកាមដោយថ្លែងអំណរគុណចំពោះការចូលរួម និងពេលវេលាដ៏មានតំលៃ។<br>▪ សុន្ទរកថាបើកវគ្គ | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|

### កំណត់សម្គាល់៖

- សុន្ទរកថាបើកវគ្គតាមការគ្រោង ចំណាយតែ ៥នាទីទេ ប៉ុន្តែក្នុងករណីដែលចំណាយអស់ពេលវែង អ្នកសម្របសម្រួលគួរធ្វើយ៉ាងណាកុំឲ្យលើសពី ២០នាទី។
- ទោះយ៉ាងណា ករណីដែលសុន្ទរកថាបើក "ចំណាយពេលវែងដោយមូលហេតុមិនអាចជៀសបាន មេរៀនផ្នែកការណែនាំឲ្យស្គាល់គ្នារបស់អ្នកចូលរួម" ត្រូវកាត់ឲ្យខ្លី។
- "ការរំពឹងទុក និងវិន័យវគ្គ" និង "ការណែនាំពីវត្ថុបំណងរបៀបវារៈ និងវិធីសាស្ត្របណ្តុះបណ្តាល" គួរតែកុំឲ្យលើសពី ៥០នាទី។

### សេចក្តីផ្តើមវគ្គ៖

- សូមស្វាគមន៍ដល់លោក លោកស្រីដែលចូលរួមក្នុងវគ្គ បណ្តុះបណ្តាលស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ ក្រុង ស្រុក និងឃុំ សង្កាត់។
- ហេតុអ្វីបាន បញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការឃុំ សង្កាត់មានភាពចាំបាច់? ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមចំបងមួយសម្រាប់ប្រទេសកម្ពុជា ក្នុងការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ប្រទេសកម្ពុជាជាប្រទេសមួយដែលជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិជាទៀងទាត់ ហើយតាមកាប្រមើលមើលផលប៉ះពាល់នៃការការប្រែប្រួលនេះទំនងជានឹងមានការកើនឡើងតាមរូបភាពជាគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងកម្លាំងនៃព្យុះត្រូពិច។
- ការសិក្សាថ្មីៗអំពីអាស៊ីអាគ្នេយ៍បានរកឃើញថាប្រទេសកម្ពុជា គឺជាប្រទេសដែលងាយរងគ្រោះជាងគេនៅក្នុងតំបន់។ ការបន្សាំទៅនឹងការប្រែប្រួលការកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងកម្រិតថ្នាក់ក្រោមជាតិចាំបាច់ ។ ដំណើរការនេះក៏ប្រឈមនឹងរបាំងរាំងមួយចំនួនដែលរួមមានការខ្វះខាតថវិកា កម្រិតនៃការយល់ដឹងអំពីហានិភ័យនៃបំរែបរួលអាកាសធាតុ ការខ្វះខាតនូវសមត្ថភាពផ្នែកបច្ចេកទេស។
- សៀវភៅណែនាំបច្ចេកទេស ស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានរៀបចំឡើងដែលមាន ៥ ជំពូក ដើម្បីប្រើប្រាស់សៀវភៅណែនាំបច្ចេកទេសនេះឱ្យមានប្រសិទ្ធភាពក្រុង ស្រុក និងឃុំ សង្កាត់ត្រូវយល់ច្បាស់ពីខ្លឹមសារសៀវភៅនេះ។ វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់នូវចំណេះដឹងក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក និងឃុំ សង្កាត់។
- **គោលបំណងមេរៀន នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច៖**
  - រៀបរាប់ និងពន្យល់បានអំពីគោលដៅ គោលបំណង និងកាលវិភាគវគ្គ
  - បញ្ជាក់គោលការណ៍សម្រាប់អនុវត្តន៍ក្នុងវគ្គបណ្តុះបណ្តាល។

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ២០នាទី | **២. ការណែនាំឱ្យស្គាល់សមាសភាពមកពីក្រុង ស្រុក និងឃុំ សង្កាត់នីមួយៗ**<br>**ជំរើសទី១**<br>១. អ្នកសម្របសម្រួលសរសេរឈ្មោះក្រុង ស្រុក និងឃុំ សង្កាត់របស់សិក្ខាកាមដែលបាន ចូលរួមក្នុងវគ្គដាក់លើក្រដាសពណ៌ រួចបិទវាតាមជញ្ជាំង ឬកម្រាលឥដ្ឋ ដែលចម្ងាយពីគ្នាប្រហែល២ម៉ែត្រ<br>២. អ្នកសម្របសម្រួលអញ្ជើញអ្នកចូលរួមឱ្យទៅឈរតាមក្រុង ស្រុក និងឃុំ សង្កាត់របស់ខ្លួន (ដែលសរសេរលើក្រដាសពណ៌នោះ)<br>៣. ក្រុមនីមួយៗ ត្រូវចាត់តាំងតំណាងម្នាក់ ដើម្បីរាយការណ៍ដល់ក្រុមធំអំពី ៖<br>ប្រាប់ឈ្មោះក្រុង ស្រុក និងឃុំ សង្កាត់<br>ចំនួនសមាជិកសរុប (ត្រូវបញ្ជាក់ពីចំនួនស្ត្រីផង)<br>មកពីក្រុង ស្រុក និងឃុំ សង្កាត់ និងតួនាទី<br>៤. ក្រុមអ្នកសម្របសម្រួលត្រូវរាយការណ៍ដែរ<br><br>**ជម្រើសទី២**<br>១. ស្វាគមន៍អ្នកចូលរួម និងណែនាំខ្លួនចំពោះក្រុម<br>២. អ្នកសម្របសម្រួលណែនាំទៅក្រុមថា យើងបង្កើតឲ្យមានទំនាក់ទំនងល្អ រវាងអ្នកចូលរួមទាំងអស់<br>៣. សូមឲ្យអ្នកចូលរួមក្រោកឈរជារង្វង់មូល<br>៤. អញ្ជើញអ្នកចូលរួមណែនាំខ្លួនទៅវិញទៅមកចំពោះក្រុម ដោយណែនាំថា<br>១. ឈ្មោះ<br>២. ការកំសាន្ត/ចំណូលចិត្ត<br>៣. កន្លែងធ្វើការដោយផ្តល់ឧទាហរណ៍មួយជាគំរូដល់ពួកគាត់<br>៥. សូមអរគុណអ្នកចូលរួម និងអញ្ជើញគាត់ឲ្យត្រលប់ទៅកន្លែងដើមវិញ | |
| ១០នាទី | **៣. បទបង្ហាញគោលដៅ គោលបំណង និងកាលវិភាគវគ្គបណ្តុះបណ្តាល**<br>▪ អ្នកសម្របសម្រួលត្រូវរៀបចំជាស្រេចនូវ គោលដៅ គោលបំណង និង កាលវិភាគនៃវគ្គបណ្តុះបណ្តាលដាក់លើក្រដាសផ្ទាំងធំ ឬជាស្លាយ (មើលលំអិតក្នុងឯកសារដែលបានភ្ជាប់)<br>▪ អ្នកសម្របសម្រួលបង្ហាញ គោលដៅ គោលបំណង និងកាលវិភាគនៃ វគ្គបណ្តុះបណ្តាលដោយសង្ខេប។ | បទបង្ហាញទី១ ស្តីពី គោលដៅគោលបំណង និងកាលវិភាគ |
| ២០នាទី | **៤. ការបង្កើតគោលការណ៍សម្រាប់អនុវត្ត និងបង្កើតក្រុមគ្រប់គ្រងថ្នាក់**<br>▪ អ្នកសម្របសម្រួលកំណត់គោលការណ៍មួយចំនួន សម្រាប់អនុវត្តន៍ក្នុងវគ្គ បណ្តុះបណ្តាល ដូចខាងក្រោម ៖<br>- សូមបិទសំឡេងទូរស័ព្ទ<br>- គោរពពេលវេលា<br>- ស្តាប់ដោយយកចិត្តទុកដាក់ និងផ្តល់យោបល់ក្នុងន័យស្ថាបនា<br>- ពេលមានយោបល់ ឬសំណួរត្រូវលើកដៃ | ក្រដាសផ្ទាំងធំ ដែលបាន សរសេរ គោលការណ៍ របស់វគ្គ |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | - មានឆន្ទៈចែករំលែកបទពិសោធន៍ និងបើកចិត្តទូលាយរៀនពីអ្នកដទៃ<br>■ អ្នកសម្របសម្រួលត្រូវកំណត់ម៉ោងរៀនដូចខាងក្រោម ៖<br>- ព្រឹក ៖ ចូលម៉ោង ០៨.០០ ចេញម៉ោង ១២.០០<br>សម្រាកអាហារសម្រន់ពីម៉ោង ០៩.៣០ ដល់ម៉ោង ០៩.៤៥<br>- ល្ងាច ៖ ចូលម៉ោង ១៤.០០ ចេញម៉ោង ១៧.៣០<br>សម្រាកអាហារសម្រន់ពីម៉ោង ១៥.៣០ ដល់ម៉ោង ១៥.៤៥<br>■ អ្នកសម្របសម្រួលចែកសិក្ខាកាមជា៣ក្រុម ដើម្បីគ្រប់គ្រងតាមថ្ងៃនីមួយៗ ៖<br>- កុម្រទី១ គ្រប់គ្រងថ្ងៃទី១<br>- ក្រុមទី២ គ្រប់គ្រងថ្ងៃទី២<br>- ក្រុមទី៣ គ្រប់គ្រងថ្ងៃទី៣<br>■ តួនាទីរបស់ក្រុមគ្រប់គ្រងថ្នាក់ មានដូចខាងក្រោម ៖<br>- រំលឹកមេរៀនពេលព្រឹក<br>- គ្រប់គ្រងពេលវេលា<br>- រំលឹកគោលការណ៍វគ្គ<br>- ដឹកនាំលេងល្បែងថាមពល<br>- ជួយអ្នកសម្របសម្រួល តាមការចាំបាច់ | |
| | **៥. ការវាយតម្លៃចំណេះដឹងសិក្ខាកាមមុនវគ្គបណ្តុះបណ្តាល**<br>■ អ្នកសម្របសម្រួលចែកបញ្ជីសំណួរវាយតម្លៃមុនវគ្គ និងណែនាំអំពីរបៀបបំពេញចម្លើយ ដល់សិក្ខាកាម<br>■ សិក្ខាកាមអនុវត្តកិច្ចការដោយផ្ទាល់ខ្លួន ក្នុងរយៈពេល២០នាទី<br>■ ចប់ការធ្វើលំហាត់នេះ អ្នកសម្របសម្រួលប្រមូលកិច្ចការពីសិក្ខាកាម។ | បញ្ជីសំណួរវាយតម្លៃមុនវគ្គ |
| ៥នាទី | **៦. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>■ សង្ខេបមេរៀន<br>■ តើអ្នកបានរៀនចំណុចសំខាន់អ្វីខ្លះ ពីមេរៀននេះ? | |

# គោលដៅ គោលបំណង និងកាលវិភាគវគ្គបណ្តុះបណ្តាល

**ស្តីពី**
**ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ**
**ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក និងឃុំ សង្កាត់**

- **គោលដៅ ៖** សិក្ខាមកាម ដែលបានចូលរួមវគ្គបណ្តុះបណ្តាលមានការកើនឡើងនូវចំណេះដឹង ជំនាញ និង សមត្ថភាពក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុង ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក និងឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព។

- **គោលបំណង ៖** ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលសិក្ខាកាមនឹងអាច ៖
  - រៀបរាប់ និងពន្យល់បានអំពីគោលគំនិតសំខាន់ៗនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក និងឃុំ សង្កាត់
  - បង្ហាញបានអំពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាសកល និងនៅកម្ពុជា
  - ពន្យល់បានអំពីគោលការណ៍ និងនីតិវិធីសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក និងឃុំ សង្កាត់
  - ពន្យល់បានអំពីគោលការណ៍នៃអនុវត្តឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ
  - ពន្យល់បានអំពីការអនុវត្តឧបករណ៍សិក្សាការកាត់បន្ថយតាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA)
  - ពន្យល់បានអំពីការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ
  - ពន្យល់បានអំពីដំណើរបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុក និងឃុំ សង្កាត់។

# កាលវិភាគបណ្តុះបណ្តាល

| | ប្រធានបទ | ធនធានអ្នកសម្របសម្រួល |
|---|---|---|
| | **ថ្ងៃទី ១** | |
| ០៨:០០-០៩:៣០ | ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១០:១៥ | មេរៀនទី១ ៖ បរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាសកល | (វីឌីអូខ្លីទី១) |
| ១០:១៥-១០:៤៥ | មេរៀនទី១ ៖ បរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការនានាសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាសកល | (បទបង្ហាញទី១) |
| ១០:៤៥-១១:១៥ | មេរៀនទី១ ៖ បរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការនានាសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា | (វីឌីអូខ្លីទី២) |
| ១២:០០-១៤:០០ | មេរៀនទី១ ៖ បរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការនានាសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា | (បទបង្ហាញទី២) |
| ១២:០០-១៤:០០ | **សម្រាកថ្ងៃត្រង់** | ១២:០០-១៤:០០ |
| ១៤:០០-១៤:២០ | ល្បែងថាមពល | ១៤:០០-១៤:២០ |
| ១៤:២០-១៥:០០ | មេរៀនទី២ ៖ ឧបករណ៍ គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ | ១៤:២០-១៥:០០ |
| ១៥:០០-១៥:៣០ | មេរៀនទី២ ៖ ពិភាក្សា និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ | ១៥:០០-១៥:៣០ |
| ១៥:៣០-១៥:៤៥ | **សម្រាកអាហារសម្រន់** | ១៥:៣០-១៥:៤៥ |
| ១៥:៤៥-១៦:១៥ | មេរៀនទី២ ៖ ពិភាក្សា និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ | ១៥:៤៥-១៦:១៥ |
| ១៦:១៥-១៦:៥៥ | មេរៀនទី២ ៖ បង្ហាញលទ្ធផលក្រុមពិភាក្សា និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ | ១៦:១៥-១៦:៥៥ |
| ១៦:៥៥-១៧:៣០ | សង្ខេបឡើងវិញនូវការបណ្តុះបណ្តាលថ្ងៃទី១ | ១៦:៥៥-១៧:៣០ |
| | **ថ្ងៃទី ២** | |
| ០៨:០០-០៨:៣០ | ០៨:០០-០៨:៣០ ការរំលឹកឡើងវិញនូវថ្ងៃទី១ | បទបង្ហាញ |
| ០៨:៣០-០៩:៣០ | ០៨:៣០-០៩:៣០ មេរៀនទី៣ ៖ ឧបករណ៍ វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA): ការវិភាគនិន្នាការការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤ | |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១១:០០ | មេរៀនទី៣ ៖ ក្រុមពិភាក្សានិងវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ | ក្រុមពិភាក្សា |
| ១១:០០-១២:០០ | មេរៀនទី៣ ៖ ក្រុមពិភាក្សា និងវិភាគការប្រែប្រួលអាកាសធាតុទម្រង់ H ទាំង៤ | ក្រុមពិភាក្សា |
| ១៥:៣០-១៥:៤៥ | **សម្រាកថ្ងៃត្រង់** | |
| ១៥:៤៥-១៦:៣០ | មេរៀនទី៣ ៖ ពិភាក្សា និងកត់ត្រាលទ្ធផលនៃការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤ ចូលក្នុងតារាងលទ្ធផល | ក្រុមពិភាក្សា |
| ១៦:៣០-១៧:០០ | មេរៀនទី៣ ៖ បង្ហាញលទ្ធផលការកត់ត្រាលទ្ធផលនៃការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤ ចូលក្នុងតារាងលទ្ធផល | តំណាងក្រុមពិភាក្សា |
| ១៧:០០-១៧:៣០ | មេរៀនទី៣ ៖ សរុបមេរៀនទី៣ និងលំហាត់វាយតម្លៃចំណេះដឹង | បទបង្ហាញ |

| | ប្រធានបទ | ធនធានអ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី ៣ | |
| ០៨:០០-០៨:៣០ | ការរំលឹកឡើងវិញនូវថ្ងៃទី២ | |
| ០៨:៣០-០៩:៣០ | មេរៀនទី៤ ៖ ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ | បទបង្ហាញ |
| ០៩:៣០-០៩:៤៥ | **សម្រាកអាហារសម្រន់** | |
| ០៩:៤៥-១០:៤៥ | មេរៀនទី៤ ៖ ពិភាក្សា និងធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ | ក្រុមពិភាក្សា |
| ១០:៤៥-១១:៣០ | មេរៀនទី៤ ៖ បង្ហាញលទ្ធផលនៃការពិភាក្សា និងការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ | តំណាងក្រុមពិភាក្សា |
| ១១:៣០-១២:០០ | មេរៀនទី៤ ៖ សរុបមេរៀនទី៤ និងលំហាត់វាយតម្លៃចំណេះដឹង | បទបង្ហាញ |
| ១២:០០-១៤:០០ | **សម្រាកថ្ងៃត្រង់** | |
| ១៤:០០-១៤:២០ | ល្បែងថាមពល | |
| ១៤:២០-១៥:០០ | មេរៀនទី៥ ៖ ដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | បទបង្ហាញ |
| ១៥:០០-១៥:៣០ | មេរៀនទី៥ ៖ ពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | ក្រុមពិភាក្សា |
| ១៥:៣០-១៥:៤៥ | **សម្រាកអាហារសម្រន់** | |
| ១៥:៤៥-១៦:១៥ | មេរៀនទី៥ ៖ បទបង្ហាញអំពីលទ្ធផលពិភាក្សា និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | តំណាងក្រុមពិភាក្សា |
| ១៦:១៥-១៦:៤៥ | មេរៀនទី៥ ៖ សរុបមេរៀនទី៥ និងលំហាត់វាយតម្លៃចំណេះដឹង | បទបង្ហាញ |
| ១៦:៤៥-១៧:៣០ | ការសន្និដ្ឋានបញ្ចប់វគ្គបណ្តុះបណ្តាល | |

# បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុន និងក្រោយ វគ្គបណ្តុះបណ្តាល

| ឈ្មោះ ៖ ...................................................... | ភេទ ៖ ........................ | រយៈពេល ៖ ២០ នាទី ថ្ងៃទី.............. ខែ................. ឆ្នាំ២០១៤ |
|---|---|---|

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើធាតុអាកាសជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) គឺការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) គឺជាការប្រែប្រួលនៃកំដៅ

**២.តើការប្រែប្រួលអាកាសធាតុជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) ការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) រាល់ការប្រែប្រួលអាកាសធាតុកន្លងទៅដោយសាការផ្លាស់ប្តូររបស់ធម្មជាតិ ឬបណ្តាលមកពីមនុស្ស

**៣.តើការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាអ្វី?**

ក) ដាក់បញ្ចូលសកម្មភាពអភិវឌ្ឍន៍កសិកម្មទៅក្នុងផែនការនានា

ខ) យល់ដឹងពីការប្រែប្រួលអាកាសធាតុ

គ) គឺជាការដាក់បញ្ចូលនូវបញ្ហាការប្រែប្រួលអាកាសធាតុ និងដំណោះស្រាយទៅក្នុងសកម្មភាពស្នូលការធ្វើផែនការ ការគ្រប់គ្រង និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រសួងមន្ទីរ អង្គការ ឬកម្មវិធី គោលនយោបាយនានាដែលនឹងធ្វើឲ្យមានការផ្លាស់ប្តូរនូវប្រតិបត្តិការ និងលទ្ធផលនាពេលអនាគត

**៤.តើឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយជាអ្វី?**

ក) គឺជាឧបករណ៍សម្រាប់វាយតម្លៃការប្រែប្រួលអាកាសធាតុ

ខ) គឺជាឧបករណ៍សម្រាប់វាយតម្លៃគម្រោងការប្រែប្រួលអាកាសធាតុ

គ) គឺជាឧបករណ៍សម្រាប់សិក្សា វាយតម្លៃ និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់

**៥.តើការវាយតម្លៃអំពីការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ជាអ្វី?**

ក) ជាឧបករណ៍ ឬវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍មួយពីការប្រែប្រួលអាកាសធាតុ

ខ) រៀបចំផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

គ) យល់ដឹងពីការប្រែប្រួលអាកាសធាតុ

**៦.តើការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយជាអ្វី?**

ក) ជាវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍មួយ ពីការប្រែប្រួល អាកាសធាតុ

ខ) គឺជាការសិក្សា និងវាយតម្លៃពីហានិភ័យនៃគ្រោះមហន្តរាយលើគម្រោងវិនិយោគឃុំ សង្កាត់

គ) គឺជាការសិក្សា និងកំណត់នូវចំណាត់ថ្នាក់គ្រោះមហន្តរាយ និងវិធានការសមស្របនានា ក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់

**៧.តើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវធ្វើចាប់ពីជំហានទីប៉ុន្មាន?**

ក) ជំហានទី៣

ខ) ជំហានទី២

គ) ជំហានទី១

សូមបង្ហាញពីចំណេះដឹងរបស់អ្នក ដោយគូសរង្វង់មូលលើលេខនៃខ្នាត ដូចខាងក្រោម ៖
**បញ្ជាក់ ៖** ១ = មិនចេះសោះ ១០ = ចេះដឹង និងយល់ច្បាស់

១

៨.តើអ្នកមានការយល់ដឹងអំពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

១

៩.តើអ្នកមានការយល់ដឹងអំពីឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយកម្រិតណា?

១

១០.តើអ្នកមានការយល់ដឹងអំពីដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការក្រុង ស្រុក និងឃុំ សង្កាត់កម្រិតណា?

១

# បញ្ជីសំណួរវាយតម្លៃចំណេះដឹងមុន និងក្រោយវគ្គបណ្តុះបណ្តាល

| ឈ្មោះ ៖ ........................................ | ភេទ ៖ ........................ | រយៈពេល ៖ ២០ នាទី ថ្ងៃទី.............. ខែ................. ឆ្នាំ២០១៩ |
|---|---|---|

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើធាតុអាកាសជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

✔ ខ) គឺការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) គឺជាការប្រែប្រួលនៃកំដៅ

**២.តើការប្រែប្រួលអាកាសធាតុជាអ្វី?**

✔ ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) ការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) រាល់ការប្រែប្រួលអាកាសធាតុកន្លងទៅដោយសាការផ្លាស់ប្តូររបស់ធម្មជាតិ ឬបណ្តាលមកពីមនុស្ស

**៣.តើការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាអ្វី?**

ក) ដាក់បញ្ចូលសកម្មភាពអភិវឌ្ឍន៍កសិកម្មទៅក្នុងផែនការនានា

ខ) យល់ដឹងពីការប្រែប្រួលអាកាសធាតុ

✔ គ) គឺជាការដាក់បញ្ចូលនូវបញ្ហាការប្រែប្រួលអាកាសធាតុ និងដំណោះស្រាយទៅក្នុងសកម្មភាពស្នូលការធ្វើផែនការ ការគ្រប់គ្រង និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រសួងមន្ទីរ អង្គការ ឬកម្មវិធី គោលនយោបាយនានាដែលនឹងធ្វើឲ្យមានការផ្លាស់ប្តូរនូវប្រតិបត្តិការ និងលទ្ធផលនាពេលអនាគត

**៤.តើឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយជាអ្វី?**

ក) គឺជាឧបករណ៍សម្រាប់វាយតម្លៃការប្រែប្រួលអាកាសធាតុ

ខ) គឺជាឧបករណ៍សម្រាប់វាយតម្លៃគម្រោងការប្រែប្រួលអាកាសធាតុ

✔ គ) គឺជាឧបករណ៍សម្រាប់សិក្សា វាយតម្លៃ និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់

**៥.តើការវាយតម្លៃអំពីការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ជាអ្វី?**

✔ ក) ជាឧបករណ៍ ឬវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍មួយពីការប្រែប្រួលអាកាសធាតុ

ខ) រៀបចំផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

គ) យល់ដឹងពីការប្រែប្រួលអាកាសធាតុ

**៦.តើការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយជាអ្វី?**

ក) ជាវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍មួយ ពីការប្រែប្រួល អាកាសធាតុ

ខ) គឺជាការសិក្សា និងវាយតម្លៃពីហានិភ័យនៃគ្រោះមហន្តរាយលើគម្រោងវិនិយោគឃុំ សង្កាត់

✔ គ) គឺជាការសិក្សា និងកំណត់នូវចំណាត់ថ្នាក់គ្រោះមហន្តរាយ និងវិធានការសមស្របនានា ក្នុងពេលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់

**៧.តើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនកាអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវធ្វើចាប់ពីជំហានទីប៉ុន្មាន?**

ក) ជំហានទី៣

ខ) ជំហានទី២

✔ គ) ជំហានទី១

សូមបង្ហាញពីចំណេះដឹងរបស់អ្នក ដោយគូសរង្វង់មូលលើលេខនៃខ្នាត ដូចខាងក្រោម ៖
**បញ្ជាក់ ៖** ១ = មិនចេះសោះ    ១០ = ចេះដឹង និងយល់ច្បាស់

១

៨.តើអ្នកមានការយល់ដឹងអំពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

១

៩.តើអ្នកមានការយល់ដឹងអំពីឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយកម្រិតណា?

១

១០.តើអ្នកមានការយល់ដឹងអំពីដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការក្រុង ស្រុក និងឃុំ សង្កាត់កម្រិតណា?

១

# ប្លង់មេរៀនទី ១. បរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច ៖
- ពន្យល់អំពីបរិបទទូទៅនៃការប្រែប្រួលអាកាសធាតុ
- បង្ហាញអំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ
- រៀបរាប់អំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- បង្ហាញអំពីវិធានការនានាសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**ខ្លឹមសារសំខាន់** បង្ហាញអំពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**រយៈពេល** ១៨០នាទី

**សម្ភារៈ**


ក្រដាសផ្ទាំងធំ


កាំបិត


ស្កុត


កន្ត្រៃ


ហ្វឺត


ក្រដាសពណ៌


ក្ដារខៀន


ម៉ាស៊ីនបញ្ចាំង LCD/OHP


ផ្ទាំងបញ្ចាំង LCD/OHP


សៀវភៅណែនាំបច្ចេកទេសស្តីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក និងឃុំ សង្កាត់ជំពូកទី១


ខ្សែ VIDEO ខ្លីទី១ និងទី២

**វិធីសាស្ត្រ** បំផុសគំនិត ចាក់ខ្សែវីឌីអូ និងបទបង្ហាញ

## សកម្មភាពសម្របសម្រួលមេរៀន

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្តីផ្តើម និងគោលបំណងមេរៀន**<br>▪ សេចក្តីផ្តើម៖ ការប្រែប្រួលអាកាសធាតុជាបញ្ហាសកល ប៉ុន្តែការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមចំបងមួយសម្រាប់ប្រទេសកម្ពុជាក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានជួបប្រទះនូវគ្រោះ | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | មហន្តរាយធម្មជាតិញឹកញាប់ ហើយតាមការប្រមើលមើល ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនេះទំនងជានឹងមានការកើនឡើងតាមរូបភាពជាគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងកម្លាំងនៃព្យុះត្រូពិច។ ការសិក្សាថ្មីៗនៅអាស៊ីអាគ្នេយ៍បានរកឃើញថាប្រទេសកម្ពុជា គឺជាប្រទេសដែលងាយរងគ្រោះជាងគេនៅក្នុងតំបន់។<br><br>បង្ហាញគោលបំណង ៖ នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច ៖<br>- ពន្យល់អំពីបរិបទទូទៅនៃការប្រែប្រួលអាកាសធាតុ<br>- បង្ហាញអំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុ<br>- រៀបរាប់អំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ<br>- បង្ហាញអំពីវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | |
| ៣០នាទី | **២. បរិបទទូទៅនៃការប្រែប្រួលអាកាសធាតុ**<br>**ចាក់ខ្សែវីឌីអូខ្លីទី១ ស្តីពីការប្រែប្រួលអាកាសធាតុជាសកល មុនចាក់បញ្ចាំងខ្សែវីឌីអូ អ្នកសម្របសម្រួលត្រូវឲ្យសិក្ខាកាមត្រៀមកត់ត្រានូវ ៖**<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>- វិធានការបន្សាំទៅការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។<br>▪ អ្នកសម្របសម្រួលចាក់បញ្ចាំងខ្សែវីឌីអូខ្លីទី១<br>**នៅពេលបញ្ចប់វីឌីអូ អ្នកសម្របសម្រួល សួរទៅអ្នកចូលរួម តើគេបានដឹងអ្វីខ្លះពីខ្សែវីឌីអូ?**<br>▪ អ្នកសម្របសម្រួលកត់ត្រានូវអ្វីដែលអ្នកចូលរួមបានយល់ដឹង ដូចជា៖<br>- វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>- ការកើនឡើងនូវកំដៅ<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>- វិធានការបន្សាំទៅការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | ខ្សែវីឌីអូទី១<br>ក្រដាសផ្ទាំងធំ<br>ហ្វឺត |
| ៣០នាទី | **៣. បរិបទទូទៅនៃការប្រែប្រួលអាកាសធាតុជាសកល**<br>▪ បទបង្ហាញ ស្តីពីបរិបទនៃការប្រែប្រួលអាកាសធាតុជាសកល ៖<br>អ្នកសម្របសម្រួលសួរបំផុសគំនិតមួយចំនួន មុននឹងធ្វើបទបង្ហាញ ៖<br>- និយមន័យនៃអាកាសធាតុ<br>- និយមន័យនៃការប្រែប្រួលអាកាសធាតុ<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុ<br>- និយមន័យ ឧស្ម័នផ្ទះកញ្ចក់<br>- វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | បទបង្ហាញៈ ជំពូក១ ស្តីពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុជាសកល |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ២០នាទី | ចុងបញ្ចប់បទបង្ហាញអ្នកសម្របសម្រួលអាចសួរនូវសំណួរ និងអត្ថន័យនៃពាក្យគន្លឹះៗទាំងអស់ឡើងវិញ។ | |
| | **៤. បរិបទទូទៅនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា**<br>■ ការចាក់ខ្សែវីឌីអូខ្លីទី២ ស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា មុនចាក់បញ្ចាំងខ្សែវីឌីអូ អ្នកសម្របសម្រួលត្រូវឲ្យសិក្ខាកាមត្រៀមកត់ត្រានូវ ៖<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា<br>- វិធានការបន្សាំទៅការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា។<br>■ អ្នកសម្របសម្រួលចាក់បញ្ចាំងខ្សែវីឌីអូខ្លីទី២<br>**នៅពេលបញ្ចប់វីឌីអូ អ្នកសម្របសម្រួល សួរទៅអ្នកចូលរួម តើគេបានដឹងអ្វីខ្លះពីខ្សែវីឌីអូ ឬ តើអ្នកចូលរួមយល់ឃើញដូចម្តេច?**<br>■ អ្នកសម្របសម្រួលកត់ត្រានូវអ្វីដែលអ្នកចូលរួមបានយល់ដឹង ដូចជា៖<br>- ការកើនឡើងនូវកំដៅនៅកម្ពុជា<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជា<br>- វិធានការបន្សាំទៅការប្រែប្រួលអាកាសធាតុ។ | ខ្សែវីឌីអូទី២ |
| ៣០នាទី | **៥. បរិបទទូទៅនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា**<br>■ **បទបង្ហាញ ស្តីពីបរិបទទូទៅនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ៖ អ្នកសម្របសម្រួលគួរសួរបំផុសគំនិតមួយចំនួន មុននឹងធ្វើបទបង្ហាញ ៖**<br>- បរិបទទូទៅនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា<br>- មូលហេតុនៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា<br>- ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា<br>- វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា<br>**ចុងបញ្ចប់នៃបទបង្ហាញ អ្នកសម្របសម្រួលគួរសួរសំណួរ និងអត្ថន័យនៃពាក្យគន្លឹះៗទាំងអស់ឡើងវិញ។** | បទបង្ហាញៈ ជំពូក១ ស្តីពីបរិបទទូទៅ មូលហេតុ ផលប៉ះពាល់ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| ១៥នាទី | **៦. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>■ សង្ខេបមេរៀន ៖<br>- អ្នកសម្របសម្រួលរៀបចំគោលគំនិតមេរៀនសំខាន់ៗ ដាក់លើក្រដាសពណ៌ ដែលមានរូបរាងដូចខាងក្រោម ដើម្បីបង្ហាញដល់សិក្ខាកាម ៖<br> | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ■ **វាយតម្លៃចំណេះដឹងក្រោយមេរៀន ៖**<br>អ្នកសម្របសម្រួលវាយតម្លៃចំណេះដឹងរបស់សិក្ខាកាមក្រោយមេរៀន ដោយប្រើប្រភេទសំណួរជ្រើសរើសចម្លើយ តាមរយៈ ការបញ្ចាំងស្លាយអ្នកសម្របសម្រួលផ្តល់ចម្លើយ និងបញ្ជាក់ពីមូលហេតុរបស់វា។ | លំហាត់<br>បញ្ជីសំណួរ<br>ជ្រើសរើស<br>ចម្លើយ |

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើធាតុអាកាសជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) គឺការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) គឺជាការប្រែប្រួលនៃកំដៅ

**២.តើការប្រែប្រួលអាកាសធាតុជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) ការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) រាល់ការប្រែប្រួលអាកាសធាតុកន្លងទៅដោយសាការផ្លាស់ប្តូររបស់ធម្មជាតិ ឬបណ្តាលមកពីមនុស្ស

**៣.តើហេតុអ្វីបានជាប្រទេសកម្ពុជាងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ?**

ក) ព្រោះប្រទេសកម្ពុជាមានធនធានធម្មជាតិច្រើន

ខ) ព្រោះប្រទេសកម្ពុជាមានតំបន់ភ្នំ និងព្រៃឈើច្រើន

គ) ព្រោះប្រទេសកម្ពុជាជាប្រទេសកសិកម្ម មានបច្ចេកវិទ្យាទាប សមត្ថភាពបន្សាំទាប និងជាប្រទេសក្រីក្រ

**៤.តើព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជាមានអ្វីខ្លះ?**

ក) មានការធ្លាក់ទឹកកក

ខ) មានរញ្ជួយដី

គ) មានគ្រោះរាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លៀងមិនទៀងទាត់ កំដៅកើនឡើង ជំនន់ទឹកភ្លៀងជាដើម

**៥.តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អ្វីខ្លះដល់កម្ពុជា?**

ក) ការប្រែប្រួលអាកាសធាតុមិនមានផលប៉ះពាល់ដល់កម្ពុជាទេ

ខ) កម្ពុជាពុំមានផលប៉ះពាល់ធ្ងន់ធ្ងរទេ

គ) ខូចហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ជីវភាពប្រជាពលរដ្ឋជាពិសេសនៅជនបទ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើធាតុអាកាសជាអ្វី?**

ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

✓ ខ) គឺការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) គឺជាការប្រែប្រួលនៃកំដៅ

**២.តើការប្រែប្រួលអាកាសធាតុជាអ្វី?**

✓ ក) មធ្យមភាគនៃព្រឹត្តិការណ៍ធាតុអាកាសក្នុងរយៈពេលលើសពី៣០ឆ្នាំឡើងទៅ

ខ) ការផ្លាស់ប្តូររាល់ម៉ោង ឬរាល់ថ្ងៃ ក្នុងបរិយាកាស

គ) រាល់ការប្រែប្រួលអាកាសធាតុកន្លងទៅដោយសាការផ្លាស់ប្តូររបស់ធម្មជាតិ ឬបណ្តាលមកពីមនុស្ស

**៣.តើហេតុអ្វីបានជាប្រទេសកម្ពុជាងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ?**

ក) ព្រោះប្រទេសកម្ពុជាមានធនធានធម្មជាតិច្រើន

ខ) ព្រោះប្រទេសកម្ពុជាមានតំបន់ភ្នំ និងព្រៃឈើច្រើន

✓ គ) ព្រោះប្រទេសកម្ពុជាជាប្រទេសកសិកម្ម មានបច្ចេកវិទ្យាទាប សមត្ថភាពបន្សាំទាប និងជាប្រទេសក្រីក្រ

**៤.តើព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជាមានអ្វីខ្លះ?**

ក) មានការធ្លាក់ទឹកកក

ខ) មានរញ្ជួយដី

✓ គ) មានគ្រោះរាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លៀងមិនទៀងទាត់ កំដៅកើនឡើង ជំនន់ទឹកភ្លៀងជាដើម

**៥.តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់អ្វីខ្លះដល់កម្ពុជា?**

ក) ការប្រែប្រួលអាកាសធាតុមិនមានផលប៉ះពាល់ដល់កម្ពុជាទេ

ខ) កម្ពុជាពុំមានផលប៉ះពាល់ធ្ងន់ធ្ងរទេ

✓ គ) ខូចហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ជីវភាពប្រជាពលរដ្ឋជាពិសេសនៅជនបទ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច

# ប្លង់មេរៀនទី ២. ឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ

**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖
- ចេះ និងអាចរៀបរាប់អំពីជំហាននៃគូសផែនទីហានិភ័យគ្រោះមហន្តរាយឃុំ សង្កាត់
- ចេះគូសផែនទីហានិភ័យគ្រោះមហន្តរាយឃុំ សង្កាត់

**ខ្លឹមសារសំខាន់**

- កំណត់តំបន់រងគ្រោះ នៃគ្រោះមហន្តរាយនៅក្នុងឃុំ សង្កាត់
- គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់

**រយៈពេល** ១៦៥នាទី

**សំភារៈ**




**វិធីសាស្ត្រ**

- បំផុសគំនិត បទបង្ហាញ និងការងារពិភាក្សាជាក្រុមតូចៗ

## សកម្មភាពសម្របសម្រួលមេរៀន

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្ដីផ្ដើម និងគោលបំណងមេរៀន**<br>សេចក្ដីផ្ដើម ៖ មេរៀនទី១ លោក លោកស្រីបានស្គាល់អំពីទិដ្ឋភាពទូទៅ នៃការប្រែប្រួលអាកាសធាតុ ដូចជា និយមន័យរបស់អាកាសធាតុការប្រែប្រួលអាកាសធាតុ មូលហេតុនៃការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងមេរៀននេះ យើងនឹងសិក្សាលម្អិត ក្នុងជំពូកទី២ ដែលផ្ដោតលើការសិក្សា | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៣០នាទី | និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ ដើម្បីជួយដល់ក្រុមការងារកសាងផែនការ និងថវិកាឃុំ សង្កាត់កំណត់បាននូវតំបន់ងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ និងចេះគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់។<br>**បង្ហាញគោលបំណង ៖** នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹង ៖<br>▪ ចេះ និងរៀបរាប់អំពីជំហានទាំង៤ ក្នុងការរៀបចំគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់<br>▪ ចេះគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់<br>▪ ប្រើប្រាស់ផែនទីនេះជាជំនួយសម្រាប់ការវិភាគស្ថានភាពក្នុងជំហានទី១នៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ | ស្លាយនៃ ជំពូកទី២ ៖ ឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ |
| ៣០នាទី | **២. ឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ**<br>ក). ការបំផុសគំនិត<br>▪ អ្នកសម្របសម្រួលគួរសួរសំណួរ ដូចខាងក្រោម ៖<br>▪ តើលោកអ្នកធ្លាប់ឮ ឬប្រើប្រាស់ឧបករណ៍គូសផែនទីហានិភ័យគ្រោះមហន្តរាយដែរឬទេ?<br>▪ តើឧបករណ៍គូសផែនទីហានិភ័យគ្រោះមហន្តរាយជាអ្វី?<br>▪ តើការរៀបចំគូសផែនទីហានិភ័យគ្រោះមហន្តរាយធ្វើឡើងនៅពេលណា?<br>▪ តើការរៀបចំគូសផែនទីហានិភ័យគ្រោះមហន្តរាយត្រូវមានសកម្មភាព ឬជំហានអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>▪ អ្នកសម្របសម្រួលសំយោគគំនិតរបស់សិក្ខាកាម។ ចម្លើយ អាចមាន ៖<br>▪ ចម្លើយសំណួរទី១ ៖ គាត់មិនដែលបានឮឈ្មោះឧបករណ៍ ឬធ្លាប់ឮតែពុំដែលបានអនុវត្ត។<br>▪ ចម្លើយសំណួរទី២ ៖ គឺជាឧបរណ៍សម្រាប់សិក្សា និងគូសផែនទីគ្រោះមហន្តរាយនៅថ្នាក់ឃុំ សង្កាត់។<br>▪ ចម្លើយសំណួរទី៣ ៖ ការគូសផែនទីហានិភ័យគ្រោះមហន្តរាយត្រូវធ្វើឡើងមុនពេលកសាងផែនការ ឬកម្មវិធីវិនិយោគឃុំ សង្កាត់។<br>▪ ចម្លើយសំណួរទី៤ ៖ ការគូសផែនទីហានិភ័យគ្រោះមហន្តរាយត្រូវធ្វើឡើងជា៤ជំហាន។<br>ខ). ការបង្ហាញ<br>▪ អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀនក្នុងជំពូកទី២ ៖ ឧបករណ៍គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈ ស្លាយ<br>▪ អ្នកសម្របសម្រួលឱ្យសិក្ខាកាមសួរសំណួរបន្ទាប់ពីការបង្ហាញចប់។ | |
| ៦០នាទី | **៣. ពិភាក្សាក្រុមតូច និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ**<br>▪ អ្នកសម្របសម្រួលចែកសិក្ខាកាមជា៣ក្រុម។ ក្រុមនីមួយៗពិភាក្សាលើប្រធានបទ នៃករណីសិក្សាទី ១ ដែលជាឧទាហរណ៍របស់ឃុំបូរីជលសារ | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ដូចខាងក្រោម ៖<br>- ក្រុមទី១ ៖គូសផែនទី និងដាក់សញ្ញាហានិភ័យនៃគ្រោះមហន្តរាយឃុំ(ក)<br>- ក្រុមទី២ ៖គូសផែនទី និងដាក់សញ្ញាហានិភ័យនៃគ្រោះមហន្តរាយឃុំ(ខ)<br>- ក្រុមទី៣ ៖គូសផែនទី និងដាក់សញ្ញាហានិភ័យនៃគ្រោះមហន្តរាយឃុំ(គ)<br>- ក្រុមនីមួយៗ ពិភាក្សាគ្នាអំពីការអនុវត្តជំហាននីមួយៗរបស់ក្រុមខ្លួន | ក្រដាសផ្ទាំងធំ<br>ហ្វឺតពិណ<br>ផែនទីឃុំ សង្កាត់<br>ដែលមានស្រាប់ |
| ៦០នាទី | **៤. បង្ហាញលទ្ធផលពិភាក្សានិងអនុវត្តការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ**<br>▪ តំណាងក្រុមនីមួយៗ ឡើងបកស្រាយអំពីជំហាននៃការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ<br>▪ អ្នកសម្របសម្រួលបូកសរុបលទ្ធផលរបស់ក្រុមនីមួយៗ និងបញ្ជាក់បន្ថែម ប្រសិនបើ មានចំណុចណាមួយមិនទាន់ច្បាស់លាស់ | បទបង្ហាញតំណាង<br>ក្រុមនិមួយៗ |
| ១៥នាទី | **៥. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>ក). ការសង្ខេបមេរៀន<br>▪ អ្នកសម្របសម្រួលរៀបចំគោលគំនិតមេរៀនសំខាន់ៗ ដាក់លើក្រដាស ពណិ ដែលមានរូបរាងដូចខាងក្រោម ដើម្បីបង្ហាញដល់សិក្ខាកាម ៖<br><br>ជំហាន១ គូសទ្រង់ទ្រាយផែនទីឃុំ ឬប្រើប្រាស់ផែនទីឃុំដែលមានស្រាប់<br>↓<br>ជំហាន២ បន្ថែមទីតាំងហេដ្ឋារចនាសម្ព័ន្ធ<br><br>ជំហាន៣ គូសទីតាំង និងដាក់និមិតសញ្ញាដែលមានផលប៉ះពាល់ពីគ្រោះធម្មជាតិ<br>↓<br>ជំហាន៤ គូសពីស្ថានភាពប្រែប្រួលទិដ្ឋភាពពីមុន និងបច្ចុប្បន្នរបស់ឃុំ សង្កាត់ | |
| ១៥នាទី | ខ). លំហាត់ វាយតម្លៃចំណេះដឹងក្រោយមេរៀន ៖<br>▪ អ្នកសម្របសម្រួលវាយតម្លៃចំណេះដឹងសិក្ខាកាមក្រោយមេរៀន ដោយប្រើបញ្ជីសំណួរជ្រើសរើសចម្លើយតាមរយៈការបញ្ចាំងស្លាយ<br>▪ អ្នកសម្របសម្រួលផ្តល់ចម្លើយ និងបញ្ជាក់ពីមូលហេតុរបស់វា | លំហាត់<br>បញ្ជីសំណួរ ជ្រើសរើស<br>ចម្លើយ |

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១. តើការគូសផែនទីហានិភ័យគ្រោះមហន្តរាយឃុំ សង្កាត់មានប៉ុន្មានជំហាន?**

ក). ៥ ជំហាន

ខ). ៦ ជំហាន

គ). ៤ ជំហាន

**២. តើជំហានទី១ត្រូវគូសអ្វី?**

ក). គូសទ្រង់ទ្រាយផែនទីឃុំ សង្កាត់ ឬប្រើប្រាស់ផែនទីឃុំ សង្កាត់ដែលមានស្រាប់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៣. តើជំហានទី២ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៤. តើជំហានទី៣ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៥. តើជំហានទី៤ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងបច្ចុប្បន្នរបស់ឃុំ សង្កាត់

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

# ចម្លើយសម្រាប់លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១. តើការគូសផែនទីហានិភ័យគ្រោះមហន្តរាយឃុំ សង្កាត់មានប៉ុន្មានជំហាន?**

ក). ៥ ជំហាន

ខ). ៦ ជំហាន

✓ គ). ៤ ជំហាន

**២. តើជំហានទី១ត្រូវគូសអ្វី?**

✓ ក). គូសទ្រង់ទ្រាយផែនទីឃុំ សង្កាត់ ឬប្រើប្រាស់ផែនទីឃុំ សង្កាត់ដែលមានស្រាប់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៣. តើជំហានទី២ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

✓ ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៤. តើជំហានទី៣ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

✓ គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៥. តើជំហានទី៤ត្រូវគូសអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

✓ ខ). គូសពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងបច្ចុប្បន្នរបស់ឃុំ សង្កាត់

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

# ប្លង់មេរៀនទី៣. ឧបករណ៍វាយតម្លៃការកាត់បន្ថយងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ

**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹង ៖

- ចេះវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុនៅក្នុងឃុំ សង្កាត់
- កំណត់អំពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅក្នុងឃុំ សង្កាត់
- រៀបរាប់អំពីសកម្មភាពជាអាទិភាព និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**ខ្លឹមសារសំខាន់**

- ចងក្រងព័តមានបឋមស្តីពីគ្រោះមហន្តរាយ និងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ
- ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ
- ការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុតាមទម្រង់ H ទាំង៤
- ចងក្រងព័តមានស្តីពីគ្រោះមហន្តរាយ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

**រយៈពេល** ៣០៥នាទី

**សំភារៈ**




**វិធីសាស្រ្ត**

- បំផុសគំនិត បទបង្ហាញ និងក្រុមពិភាក្សាតូចៗ

## សកម្មភាពសម្របសម្រួលមេរៀន

| | ជំហាន និងវិធីសាស្រ្ត | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្តីផ្តើម និងគោលបំណងមេរៀន**<br>សេចក្តីផ្តើម ៖<br>▪ មេរៀនទី២ លោក លោកស្រីបានស្គាល់អំពីការសិក្សា និងគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយឃុំ សង្កាត់។ ដូច្នេះមេរៀននេះយើងនឹងសិក្សាជំពូកទី៣ ដោយផ្តោតលើការសិក្សាពីការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដែលជាឧបករណ៍សម្រាប់សិក្សា និងវិភាគទិន្នន័យសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះ | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | មហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។<br>**បង្ហាញគោលបំណង ៖**<br>នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង ៖<br>▪ ចេះប្រើប្រាស់ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA)<br>▪ ពន្យល់អំពីការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ<br>▪ ពន្យល់អំពីការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុតាមទ្រង់ H<br>▪ កំណត់បាននូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុឃុំ សង្កាត់<br>▪ ចងក្រងបាននូវទិន្នន័យភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុក្រុង ស្រុក និងឃុំ សង្កាត់។ | |
| ៦០នាទី | **២. ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ**<br>**ក). ការបំផុសគំនិត**<br>▪ អ្នកសម្របសម្រួលគួរសួរសំណួរថា ៖<br>- តើលោកអ្នកធ្លាប់ឮ ឬប្រើប្រាស់ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ដែរឬទេ?<br>- តើឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ជាអ្វី?<br>- តើការរៀបចំអនុវត្តឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) នៅទីណា និងពេលណា?<br>- តើការអនុវត្តឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ត្រូវចែកចេញជាប៉ុន្មានក្រុម? ក្រុមអ្វីខ្លះ?<br>- តើអ្វីជាការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ?<br>- អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្ដារខៀន ឬក្រដាសផ្ទាំងធំ។<br>▪ អ្នកសម្របសម្រួលសំយោគគំនិតរបស់សិក្ខាកាម។ ចម្លើយ អាចមាន ៖<br>- ចម្លើយសំណួរទី១ ៖ គាត់មិនដែលបានឮឈ្មោះឧបករណ៍។<br>- ចម្លើយសំណួរទី២ ៖ គឺជាឧបរណ៍សម្រាប់សិក្សា និងប្រមូលពិតមានពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ឃុំ សង្កាត់។<br>- ចម្លើយសំណួរទី៣ ៖ ការអនុវត្តឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) គឺអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ឬសហគមន៍ ហើយត្រូវធ្វើឡើងមុនពេលកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគឃុំ សង្កាត់។<br>- ចម្លើយសំណួរទី៤ ៖ ការអនុវត្តឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) គួរចែកជា៣ ទៅ៤ ក្រុម រួមមាន ក្រុមអាជ្ញាធរ ក្រុមបុរស ក្រុមស្ត្រី ឬក្រុមយុវជន។<br>▪ ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ គឺជាការវិភាគពីព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុពីអតីតកាល បច្ចុប្បន្ន និងអនាគត។ | ក្រដាសផ្ទាំងធំ ឬ ក្ដារខៀន |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | **ខ). បទបង្ហាញខ្លឹមសារមេរៀន ជំពូកទី៣ ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA)**<br>- អ្នកសម្របសម្រួលបង្ហាញអំពីឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) ។<br>- នៅចុងបញ្ចប់នៃការបង្ហាញ អ្នកសម្របសម្រួលឱ្យសិក្ខាកាមសួរសំណួរ បន្ទាប់មក អ្នកសម្របសម្រួលពន្យល់បកស្រាយបំភ្លឺ។ | ជំពូកទី៣ ៖ ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) |
| ៧៥នាទី | **៣. ក្រុមពិភាក្សា និងអនុវត្តការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ**<br>- អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមពិភាក្សាករណីសិក្សាមេរៀនទី៣<br>- ពិភាក្សាឃុំណាមួយ ឬពិភាក្សាឃុំប៉ូវីជលសារដោយផ្អែកលើករណីសិក្សាមេរៀនទី៣ និងសំណួរខាងក្រោម៖<br>**ក. វិភាគនិន្នាការ**<br>១. ចូរវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុរបស់ឃុំណាមួយ ឬ ឃុំប៉ូវីជលសារ ករណីសិក្សាមេរៀនទី៣។ ក្រុមនីមួយៗពិភាក្សាលើការ វិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ និងដាក់ពិន្ទុពី ១ ទៅ ៥ (ដាក់ពិន្ទុ១ បើងាយរងគ្រោះតិចតួច និងដាក់ពិន្ទុ៥ បើងាយរងគ្រោះខ្លាំង)។<br>ឧទាហរណ៍តារាងវិភាគនិន្នាការដែលបានបំពេញរួច៖<br><br><br>ប្រភព: ឯកសារមគ្គុទេសក៍សម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន៖ ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (២០១២:២៥)<br>ខ. វាយតម្លៃការកាត់បន្ថយភាពរងគ្រោះពីការប្រែប្រួលអាកាសធាតុ (ទម្រង់ Hទាំង៤)<br>២. តើអ្វីជាស្ថានភាពនៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន?<br>៣. តើមានអ្វីនឹងកើតឡើងប្រសិនបើស្ថានភាពកាន់តែអាក្រក់ជាងមុនទ្វេដង ឬកាន់តែយ៉ាប់យឺនទៅ? | ក្រដាសផ្ទាំងធំហ្វិត និងតារាងដាក់ពិន្ទុនិន្នាការប្រែប្រួលអាកាសធាតុទម្រង់ H<br><br>លំហាត់ករណីសិក្សាទី៣ |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ៤. តើកត្តាអ្វីដែលជាឧបសគ្គរាំងរាអ្នកមិនឲ្យបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន?<br>៥. តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថាអាចជួយកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកនិងសហគមន៍?<br>ឧទាហរណ៍ទម្រង់គំរូ H ដែលបានបំពេញរួចៈ<br><br>ប្រភព: ឯកសារមគ្គុទេសក៍សម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋានៈ ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (២០១២:២៦) | ជំពូកទី៣ ៖<br>ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA) |
| ៧០នាទី | **៤. បង្ហាញលទ្ធផលពិភាក្សា និងអនុវត្តការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤**<br>▪ តំណាងក្រុមនីមួយៗ ឡើងបង្ហាញនូវលទ្ធផលពិភាក្សា<br>▪ អ្នកសម្របសម្រួលបូកសរុបលទ្ធផលរបស់ក្រុមនីមួយៗ និងបញ្ជាក់បន្ថែម ប្រសិនបើ មានចំណុចណាមួយមិនទាន់ច្បាស់លាស់។ | |
| ៨៥នាទី | **៥. ក្រុមពិភាក្សា និងកត់ត្រាលទ្ធផលនៃការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤**<br>▪ អ្នកសម្របសម្រួលចែកសិក្ខាកាមជា៣ក្រុម។ ក្រុមនីមួយៗពិភាក្សា និងកត់ត្រានូវលទ្ធផលវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤ ចូលក្នុងតារាងសរុបលទ្ធផល ដូចខាងក្រោម ៖<br>▪ ក្រុមទី១ ៖ តារាងលទ្ធផលឃុំ សង្កាត់ (ក)<br>▪ ក្រុមទី២ ៖ តារាងលទ្ធផលឃុំ សង្កាត់ (ខ)<br>▪ ក្រុមទី៣ ៖ តារាងលទ្ធផលឃុំ សង្កាត់ (គ) | |
| ៣០នាទី | **៦. បង្ហាញលទ្ធផលក្រុមពិភាក្សា និងកត់ត្រាលទ្ធផលនៃការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់ H ទាំង៤**<br>▪ តំណាងក្រុមនីមួយៗ ឡើងបង្ហាញនូវលទ្ធផលពិភាក្សា<br>▪ អ្នកសម្របសម្រួលបូកសរុបលទ្ធផលរបស់ក្រុមនីមួយៗ និងបញ្ជាក់បន្ថែម ប្រសិនបើ មានចំណុចណាមួយមិនទាន់ច្បាស់លាស់។ | |

<table>
<tr><th></th><th>ជំហាន និងវិធីសាស្ត្រ</th><th>ធនធាន</th></tr>
<tr><td>១៥នាទី</td><td>

**៧. ការសន្និដ្ឋានបញ្ចប់មេរៀន**

ក). ការសង្ខេបមេរៀន

- អ្នកសម្របសម្រួលរៀបចំគោលគំនិតមេរៀនសំខាន់ៗ បង្ហាញដល់សិក្ខាកាម ៖



</td><td>ក្រដាសផ្ទាំងធំ និងហ្វឺត</td></tr>
<tr><td></td><td>

ខ). លំហាត់ វាយតម្លៃចំណេះដឹងក្រោយមេរៀន ៖

- អ្នកសម្របសម្រួលវាយតម្លៃចំណេះដឹងសិក្ខាកាមក្រោយមេរៀន ដោយប្រើបញ្ជីសំណួរជ្រើសរើសចម្លើយតាមរយៈការបញ្ចាំងស្លាយ ឬក្រដាសផ្ទាំងធំ។
- អ្នកសម្របសម្រួលផ្តល់ចម្លើយ និងបញ្ជាក់ពីមូលហេតុរបស់វា។

</td><td>លំហាត់បញ្ជីសំណួរជ្រើសរើសចម្លើយ</td></tr>
</table>

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១. តើឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA)ជាអ្វី?**

ក). ជាឧបករណ៍សិក្សា និងគូសផែនទីគ្រោះមហន្តរាយ

ខ). ឧបករណ៍ប្រមូលទិន្នន័យ បញ្ហា និងតម្រូវការនៅក្នុងឃុំ

គ). ជាឧបករណ៍ ឬវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍

**២. តើ VRA ត្រូវអនុវត្តតាមរបៀបណា?**

ក). VRA ត្រូវបានរៀបចំធ្វើតាមរយៈធ្វើការប្រជុំជាមួយសហគមន៍ដោយប្រើការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់អក្សរ H

ខ). បង្កើតសិក្ខាសាលានៅថ្នាក់ស្រុក

គ). បង្រៀនពីការប្រែប្រួលអាកាសធាតុ

**៣. តើការវិភាគការប្រែប្រួលអាកាសធាតុក្នុងឧបករណ៍ VRA មានអ្វីខ្លះ?**

ក). ការចាត់ចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃកម្មវិធី

ខ). ការគូសផែនទីគ្រោះមហន្តរាយ

គ). ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ និងការវិភាគទម្រង់ H

**៤. តើអ្វីទៅជាការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ?**

ក). ការកត់ត្រាអំពីគ្រោះមហន្តរាយ

ខ). ការគូសផែនទីគ្រោះមហន្តរាយ

គ). ការវិភាគអំពីព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុដែលកើតឡើងពីអតីតកាល បច្ចុប្បន្ន និងអនាគត

**៥. តើការវិភាគការប្រែប្រួលអាកាសធាតុតាមរយៈទម្រង់ H មានប៉ុន្មានសំណួរ ?**

ក). មាន ៥ សំណួរ

ខ). មាន ៣ សំណួរ

គ). មាន ៤ សំណួរ

# ចម្លើយសម្រាប់លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១. តើឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (VRA)ជាអ្វី?**

ក). ជាឧបករណ៍សិក្សា និងគូសផែនទីគ្រោះមហន្តរាយ

ខ). ឧបករណ៍ប្រមូលទិន្នន័យ បញ្ហា និងតម្រូវការនៅក្នុងឃុំ

✓ គ). ជាឧបករណ៍ ឬវិធីសាស្ត្រដែលគេប្រើដើម្បីធ្វើការវាយតម្លៃភាពងាយរងគ្រោះរបស់សហគមន៍

**២. តើ VRA ត្រូវអនុវត្តតាមរបៀបណា?**

✓ ក). VRA ត្រូវបានរៀបចំធ្វើតាមរយៈធ្វើការប្រជុំជាមួយសហគមន៍ដោយប្រើការវិភាគនិន្នាការ ការប្រែប្រួលអាកាសធាតុ និងទម្រង់អក្សរ H

ខ). បង្កើតសិក្ខាសាលានៅថ្នាក់ស្រុក

គ). បង្រៀនពីការប្រែប្រួលអាកាសធាតុ

**៣. តើការវិភាគការប្រែប្រួលអាកាសធាតុក្នុងឧបករណ៍ VRA មានអ្វីខ្លះ?**

ក). ការចាត់ចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃកម្មវិធី

ខ). ការគូសផែនទីគ្រោះមហន្តរាយ

✓ គ). ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ និងការវិភាគទម្រង់ H

**៤. តើអ្វីទៅជាការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ?**

ក). ការកត់ត្រាអំពីគ្រោះមហន្តរាយ

ខ). ការគូសផែនទីគ្រោះមហន្តរាយ

✓ គ). ការវិភាគអំពីព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុដែលកើតឡើងពីអតីតកាល បច្ចុប្បន្ន និងអនាគត

**៥. តើការវិភាគការប្រែប្រួលអាកាសធាតុតាមរយៈទម្រង់ H មានប៉ុន្មានសំណួរ ?**

ក). មាន ៥ សំណួរ

ខ). មាន ៣ សំណួរ

✓ គ). មាន ៤ សំណួរ

# ប្លង់មេរៀនទី ៤. ឧបករណ៍ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ

**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖
- យល់ដឹង ពីការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ
- អនុវត្តការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ

**ខ្លឹមសារសំខាន់**

- ការសិក្សា និងចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយលើផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- កំណត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ
- កំណត់ជំហាននៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ
- កំណត់បាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់សម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ

**រយៈពេល**

១៨០នាទី

**សំភារៈ**




**វិធីសាស្រ្ត**

- បំផុសគំនិត បទបង្ហាញ និងការងារពិភាក្សាជាក្រុមតូចៗ

## សកម្មភាពសម្របសម្រួលមេរៀន

| ពេល | ជំហាន និងវិធីសាស្រ្ត | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្តីផ្តើម និងគោលបំណងមេរៀន**<br>- សេចក្តីផ្តើម ៖ មេរៀនទី៣ លោក លោកស្រីបានស្គាល់អំពីការវាយតម្លៃភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ។ ក្នុងមេរៀននេះ យើងនឹងសិក្សាលម្អិត ក្នុងជំពូកទី៤ ដែលផ្តោតលើការសិក្សា និងចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ ដើម្បីជួយដល់ក្រុមការងារកសាងផែនការ និងថវិកាធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយក្នុងអំឡុងពេលកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ | |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ■ **បង្ហាញគោលបំណង ៖**<br>នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹង៖<br>- ពន្យល់នូវសកម្មភាព ឬជំហានទាំង៤ ក្នុងការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ<br>- អនុវត្តការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយនៅពេលកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ | |
| ៣០នាទី | **២. ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ**<br>ក). ការបំផុសគំនិត<br>■ អ្នកសម្របសម្រួលសួរសំណួរ ដូចខាងក្រោម ៖<br>- តើលោកអ្នកធ្លាប់ឮ ឬធ្លាប់ធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយដែរឬទេ?<br>- តើការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយជាអ្វី?<br>- តើការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយគួរធ្វើឡើងនៅពេលណា?<br>- តើការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវមានជំហានអ្វីខ្លះ?<br>■ អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្រដាសផ្ទាំងធំ។<br>■ អ្នកសម្របសម្រួលសំយោគគំនិតរបស់សិក្ខាកាម។ ចម្លើយ អាចមាន ៖<br>- ចម្លើយសំណួរទី១ ៖ គាត់មិនដែលបានឮ ឬធ្លាប់លឺ និងបានអនុវត្ត។<br>- ចម្លើយសំណួរទី២ ៖ គឺជាឧបករណ៍សម្រាប់សិក្សាចាត់ថ្នាក់គ្រោះមហន្តរាយនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។<br>- ចម្លើយសំណួរទី៣ ៖ ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើឡើងក្នុងពេលកសាងផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគឃុំ សង្កាត់។<br>- ចម្លើយសំណួរទី៤ ៖ ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើឡើងជា៤ជំហាន។<br><br>ខ). ការបង្ហាញ<br>■ អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀនក្នុងជំពូកទី៤ ៖ ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ តាមរយៈស្លាយ<br>■ អ្នកសម្របសម្រួលសួរសិក្ខាកាមនូវសំណួរបន្ទាប់ពីធ្វើការបង្ហាញចប់។<br>I. តើមុនពេលធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វីខ្លះ?<br>II. តើក្នុងកំឡុងពេលធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វីខ្លះ?<br>III. តើក្រោយពេលធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វីខ្លះ?<br><br>គ). ការបង្ហាញ និងពន្យល់អំពីវិធីសាស្ត្រ “ផ្ទៀងផ្ទាត់ ឬប្រៀបធៀប” ក្នុងការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ<br>អ្នកសម្របសម្រួលចាប់ផ្តើម ដោយលើកឡើងថា ការអនុវត្តវិធីសាស្ត្រនេះក្រុមពិភាក្សា និងអនុវត្តតាមចំណុចនីមួយៗដូចខាងក្រោម៖<br>■ សូមសរសេរគ្រោះមហន្តរាយនីមួយៗឲ្យបានពីរដង (តាមជួរបញ្ឈរ និងជួរផ្តេក) ធ្វើការប្រៀបធៀបម្តងមួយគូ។ ឧទាហរណ៍ ទឹកជំនន់ និងគ្រោះរាំងស្ងួត | បទបង្ហាញជំពូកទី៤ ៖ ការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយ |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|

ទឹកជំនន់ និងព្យុះផ្គរ/រន្ទះ...។ល។

- ជម្រើសដែលទទួលបាននូវការគាំទ្រ ឬពេញចិត្តជាង ត្រូវសរសេរក្នុងប្រអប់ដែលស្ថិតនៅចន្លោះនៃការប្រៀបធៀបជម្រើសទាំងពីរ។

បន្ទាប់ពីពន្យល់ហើយអ្នកសម្របសម្រួលអនុវត្តជាក់ស្តែងអំពីការប្រៀបធៀបជាគូនេះឲ្យសិក្ខាកាមមើល។ ក្នុងការអនុវត្តសាកល្បងនេះ អ្នកសម្របសម្រួលអាចស្នើឲ្យសិក្ខាកាមចូលរួមផ្តល់យោបល់ និងសម្រេចជ្រើសរើសអំពីការប្រៀបធៀបនេះ។ ឧទាហរណ៍៖

| គ្រោះមហន្តរាយ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ព្យុះផ្គរ/រន្ទះ | ភ្លើងឆេះព្រៃ | គ្រុនចាញ់ |
|---|---|---|---|---|---|
| ទឹកជំនន់ | ✕ | ទឹកជំនន់ | ទឹកជំនន់ | ទឹកជំនន់ | ទឹកជំនន់ |
| គ្រោះរាំងស្ងួត | ✕ | ✕ | រន្ទះ | គ្រោះរាំងស្ងួត | គ្រោះរាំងស្ងួត |
| ព្យុះផ្គរ/រន្ទះ | ✕ | ✕ | ✕ | រន្ទះ | រន្ទះ |
| ភ្លើងឆេះព្រៃ | ✕ | ✕ | ✕ | ✕ | គ្រុនចាញ់ |
| គ្រុនចាញ់ | ✕ | ✕ | ✕ | ✕ | ✕ |
| **សរុបចំនួនដង** | ៤ | ២ | ៣ | ០ | ១ |

អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា តាមរយៈការអនុវត្តវិធីសាស្ត្រនេះ ក្រុមការងារអាចកំណត់បាននូវលំដាប់អាទិភាពដូចខាងក្រោម៖

| ជម្រើស | សរុបចំនួនដង | លំដាប់អាទិភាព |
|---|---|---|
| ទឹកជំនន់ | ៤ | ១ |
| ព្យុះផ្គរ/រន្ទះ | ៣ | ២ |
| គ្រោះរាំងស្ងួត | ២ | ៣ |
| គ្រុនចាញ់ | ១ | ៤ |
| ភ្លើងឆេះព្រៃ | ០ | ៥ |

៤៥នាទី

**៣. ក្រុមពិភាក្សា និងអនុវត្តការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ**

- អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមពិភាក្សាតូចៗ។ ក្រុមនីមួយៗអាចពិភាក្សាលើ ប្រធានបទនៃករណីសិក្សាទី៤ ដែលជាឧទាហរណ៍របស់ឃុំបូរីជលសារ ឬឃុំណាមួយក្នុងខេត្តរបស់ខ្លួន។ ឧទាហរណ៍៖
  - ក្រុមទី១ ៖ ពិភាក្សាធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយឃុំ (ក)
  - ក្រុមទី២ ៖ ពិភាក្សាធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយឃុំ (ខ)
  - ក្រុមទី៣ ៖ ពិភាក្សាធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយឃុំ (គ)

ក្រដាសផ្ទាំងធំ
ហ្វឺត
លំហាត់ករណីសិក្សាទី៤

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៣០នាទី | **៤. បង្ហាញលទ្ធផលនៃក្រុមពិភាក្សា និងអនុវត្តការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ**<br>▪ តំណាងក្រុមនីមួយៗ ឡើងបង្ហាញនូវលទ្ធផលពិភាក្សា<br>▪ អ្នកសម្របសម្រួលបូកសរុបលទ្ធផលរបស់ក្រុមនីមួយៗ និងបញ្ជាក់បន្ថែម | បទបង្ហាញតំណាងក្រុម |
| ១៥នាទី | **៥. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>ក). ការសង្ខេបមេរៀន<br>▪ អ្នកសម្របសម្រួលរៀបចំគោលគំនិតមេរៀនសំខាន់ៗ ដើម្បីបង្ហាញ ៖<br>ជំហាន១ ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ<br>ជំហាន២ កត់ត្រាប្រភេទគ្រោះមហន្តរាយទៅក្នុងតារាង<br>ជំហាន៣ ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក<br>ជំហាន៤ កំណត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ | |
| ១៥នាទី | ខ). លំហាត់ វាយតម្លៃចំណេះដឹងក្រោយមេរៀន ៖<br>▪ អ្នកសម្របសម្រួលវាយតម្លៃចំណេះដឹងសិក្ខាកាមក្រោយមេរៀន ដោយប្រើបញ្ជីសំណួរជ្រើសរើសចម្លើយតាមរយៈការបញ្ចាំងស្លាយ អ្នកសម្របសម្រួលផ្តល់ចម្លើយ និងបញ្ជាក់ពីមូលហេតុរបស់វា។ | លំហាត់<br>បញ្ជីសំណួរ ជ្រើសរើសចម្លើយ |

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម៖

**១. តើការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយមានប៉ុន្មានជំហាន?**

ក). ១ ជំហាន

ខ). ៣ ជំហាន

គ). ៤ ជំហាន

**២. តើជំហានទី១នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៣. តើជំហានទី២នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). កត់ត្រាប្រភេទគ្រោះមហន្តរាយទៅក្នុងតារាង

ខ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

គ). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

**៤. តើជំហានទី៣នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

ខ). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៥. តើជំហានទី៤នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

ខ). កំណត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ

គ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម៖

**១. តើការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយមានប៉ុន្មានជំហាន?**

ក). ១ ជំហាន

ខ). ៣ ជំហាន

✓ គ). ៤ ជំហាន

**២. តើជំហានទី១នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). គូសផែនទីឃុំ សង្កាត់

ខ). គូសបន្ថែមគម្រោងហេដ្ឋារចនាសម្ព័ន្ធ

✓ គ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៣. តើជំហានទី២នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

✓ ក). កត់ត្រាប្រភេទគ្រោះមហន្តរាយទៅក្នុងតារាង

ខ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

គ). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

**៤. តើជំហានទី៣នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

✓ ខ). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

គ). គូសបន្ថែមតំបន់រងផលប៉ះពាល់ដោយគ្រោះធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

**៥. តើជំហានទី៤នៃការធ្វើចំណាត់ថ្នាក់គ្រោះមហន្តរាយត្រូវធ្វើអ្វី?**

ក). ប្រៀបធៀបប្រភេទនៃគ្រោះមហន្តរាយតាមជួរបញ្ឈរ និងជួរផ្តេក

✓ ខ). កំណត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ

គ). ពិនិត្យលើគ្រោះមហន្តរាយដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

# ប្លង់មេរៀនទី ៥: ដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ

**គោលបំណង**

នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹង ៖

- ពន្យល់អំពីវិធីសាស្ត្រក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុកនិងឃុំ សង្កាត់
- បង្ហាញការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុកនិងឃុំ សង្កាត់។

**ខ្លឹមសារសំខាន់**

- បង្ហាញពីដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- បង្ហាញពីនិតិវិធីក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- កំណត់ជំហាននៃការអនុវត្តក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- រៀបចំបាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ដែលបានបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។

**រយៈពេល**

១៣៥ នាទី

**សំភារៈ**




**វិធីសាស្ត្រ**

- បំផុសគំនិត បទបង្ហាញ និងក្រុមពិភាក្សាតូចៗ

## សកម្មភាពសម្របសម្រួលមេរៀន

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. បង្ហាញសេចក្ដីផ្ដើម និងគោលបំណងមេរៀន**<br>■ សេចក្ដីផ្ដើម ៖<br>មេរៀនទី៤ លោក លោកស្រីបានស្គាល់អំពីការចាត់ចំណាត់ថ្នាក់គ្រោះមហន្តរាយ។ ក្នុងមេរៀននេះ យើងនឹងសិក្សាលម្អិត ក្នុងជំពូកទី៥ដែលផ្ដោត | |

<table>
<tr><th></th><th>ជំហាន និងវិធីសាស្ត្រ</th><th>ធនធាន</th></tr>
<tr><td></td><td>លើដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដែលអាចជួយឲ្យគណៈកម្មការកសាងផែនការ និងថវិកាឃុំ សង្កាត់អាចដាក់បញ្ចូលនូវគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។<br><br>បង្ហាញគោលបំណង ៖ នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច ៖<br>■ ពន្យល់អំពីសកម្មភាព ឬជំហានទាំង៥ ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់<br>■ រៀបរាប់អំពីសកម្មភាពក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់<br>■ ពន្យល់អំពីដំណើការ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។</td><td></td></tr>
<tr><td>៤០នាទី</td><td>២. ដំណើរការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ<br>ក). ការបំផុសគំនិត<br>■ មុននឹងធ្វើបទបង្ហាញ អ្នកសម្របសម្រួលគួរសួរសំណួរ ដូចខាងក្រោម ៖<br>- តើលោកអ្នកធ្លាប់ចូលរួមក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីក្រុង ស្រុក ឬឃុំ សង្កាត់ដែរឬទេ?<br>- តើការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីក្រុង ស្រុក ឬឃុំ សង្កាត់មានប៉ុន្មានជំហាន?<br>- តើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយត្រូវចាប់ផ្តើមពីជំហានទីប៉ុន្មាននៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ឃុំ សង្កាត់ ?<br>■ អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br>■ អ្នកសម្របសម្រួលសំយោគគំនិតរបស់សិក្ខាកាម។ ចម្លើយ អាចមាន ៖<br>- ចម្លើយសំណួរទី១ ៖ ធ្លាប់ចូលរួមក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់។<br>- ចម្លើយសំណួរទី២ ៖ ការកសាងផែនការក្រុង ស្រុកមាន៣ជំហាន ចំណែកឯការកសាងផែនការឃុំ សង្កាត់មាន៥ជំហាន។<br>- ចម្លើយសំណួរទី៣ ៖ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយគឺចាប់ពីជំហានទី១។<br><br>ខ). ការបង្ហាញ<br>• អ្នកសម្របសម្រួលបង្ហាញខ្លឹមសារមេរៀនក្នុងជំពូកទី២៖ ដំណើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយតាមរយៈស្លាយ</td><td>ស្លាយនៃ<br>ជំពូកទី៥ ៖ ដំណើរការ<br>បញ្ជ្រាបការប្រែប្រួល<br>អាកាសធាតុ</td></tr>
</table>

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ▪ អ្នកសម្របសម្រួលឱ្យសិក្ខាកាមសួរសំណួរបន្ទាប់ពីការបង្ហាញចប់។ | |
| ៣០នាទី | **៣. ពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការឃុំ សង្កាត់**<br>▪ អ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមពិភាក្សាតូចៗ។ ក្រុមនីមួយៗអាចពិភាក្សាលើ ប្រធានបទ ករណីសិក្សាទី៥ ឬ ឃុំណាមួយរបស់ខ្លួន ដូចខាងក្រោម ៖<br>- ក្រុមទី១ ៖ពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះហន្តរាយរបស់ឃុំ(ក)<br>- ក្រុមទី២ ៖ពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះហន្តរាយរបស់ឃុំ(ខ)<br>- ក្រុមទី៣ ៖ពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះហន្តរាយរបស់ឃុំ (គ)<br><br>▪ *សំណួរសម្រាប់ពិភាក្សាដែលអាចយកពីក្នុងលំហាត់ករណីសិក្សាទី៥គឺ៖*<br>**ផ្នែកកំនត់វិស័យ**<br>១. កំនត់វិស័យដែលងាយរងផលប៉ះពាល់ដោយបំរែបំរួលអាកាសធាតុ<br>**ផ្នែកស្រង់ទិន្នន័យ**<br>២. បញ្ចូលទិន្នន័យពីការវិភាគទាំងអស់ក្នុងករណីសិក្សាមេរៀន២ មេរៀន៣ និងមេរៀន៤ (រួមទាំងទិន្នន័យពីការវិភាគនិន្នាការ និងការវាយតម្លៃការកាត់បន្ថយភាពរងគ្រោះពីការប្រែប្រួលអាកាសធាតុ ទម្រង់ H ទាំង៥) ទៅក្នុង<br>- តារាង១.១ របស់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់?<br>- តារាង២.១ របស់កម្មវិធីវិនិយោគឃុំ សង្កាត់?<br>**ក្រោយស្រង់ទិន្នន័យ**<br>៣. តើត្រូវធ្វើអ្វីខ្លះ មុនពេលបញ្ចូលការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់?<br>៤. តើត្រូវធ្វើអ្វីខ្លះ ក្នុងកំឡុងបញ្ចូលការបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់?<br>៥. តើត្រូវធ្វើអ្វីខ្លះ ក្រោយពេលបញ្ចូលនូវគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់? | ក្រដាសផ្ទាំងធំ និងហ្វឺត<br><br>លំហាត់ករណីសិក្សាទី៥ |
| ៣០នាទី | **៤. បង្ហាញលទ្ធផលនៃក្រុមពិភាក្សា និងអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការឃុំ**<br>▪ តំណាងក្រុមនីមួយៗ ឡើងបង្ហាញនូវលទ្ធផលពិភាក្សា<br>▪ អ្នកសម្របសម្រួលបូកសរុបលទ្ធផលរបស់ក្រុមនីមួយៗ និងបញ្ជាក់បន្ថែម ប្រសិនបើ មានចំណុចណាមួយមិនទាន់ច្បាស់លាស់។ | បទបង្ហាញ តំណាងក្រុម |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| | ចំណាំ៖ តារាង ១.១ របស់ផែនការអភិវឌ្ឍឃុំ និងតារាង ២.១ របស់កម្មវិធីវិនិយោគឃុំ មាននៅក្នុងសៀវភៅណែនាំបច្ចេកទេស ស្ដីពីការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ ឃុំ សង្កាត់ និងមាននៅស្លាយ១២ និង១៣របស់មេរៀនទី៥។ | |
| ១៥នាទី | **៥. ការសន្និដ្ឋានបញ្ចប់មេរៀន**<br>ក). ការសង្ខេបមេរៀន<br>▪ អ្នកសម្របសម្រួលរៀបចំគោលគំនិតមេរៀនសំខាន់ៗ ដាក់លើក្រដាស ពណ៌ ដែលមានរូបរាងដូចខាងក្រោម ដើម្បីបង្ហាញដល់សិក្ខាកាម ៖ | |

ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ជារួមនិងការកែប្រែដែលត្រូវបានស្នើឡើងត្រូវបានបង្ហាញនៅក្នុងទិដ្ឋភាពដូចខាងក្រោម



ដំណើរការនៃការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ជាមួយនិងការកែប្រែ
ដែលត្រូវបានស្នើឡើងត្រូវបានបង្ហាញនៅក្នុងទិដ្ឋភាពដូចខាងក្រោម

- វគ្គនៃកម្មវិធីវិនិយោគឃុំ សង្កាត់
- ជំហានទី១៖ការពិនិត្យមើលឡើងវិញ ពីបញ្ហានិងតម្រូវការ ← ឧបករណ៍បន្ថែមសម្រាប់ធ្វើបង្កើនការ យល់ដឹងអំពីស្ថានភាពមូលដ្ឋាន និង កំណត់ដំណោះស្រាយបានកាន់តែប្រសើ
- ជំហានទី២៖ការរៀបចំគម្រោង វិនិយោគឃុំ សង្កាត់ ← ចំណាត់ថ្នាក់នៃភាពងាយ រងគ្រោះរបស់គម្រោង
- ជំហានទី៣៖សិក្ខាសាលា សមាហរនកម្មថ្នាក់ស្រុក
- ជំហានទី៤៖ការអនុម័ត កម្មវិធីវិនិយោគឃុំ សង្កាត់
- ជំហានទី៥៖ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធី វិនិយោគឃុំ សង្កាត់

| | ជំហាន និងវិធីសាស្រ្ត | ធនធាន |
|---|---|---|
| ១៥នាទី | **ខ). លំហាត់ វាយតម្លៃចំណេះដឹងក្រោយមេរៀន ៖**<br>▪ អ្នកសម្របសម្រួលវាយតម្លៃចំណេះដឹងសិក្ខាកាមក្រោយមេរៀន ដោយប្រើបញ្ជីសំណួរជ្រើសរើសចម្លើយតាមរយៈការបញ្ចាំងស្លាយ<br>▪ អ្នកសម្របសម្រួលផ្តល់ចម្លើយ និងបញ្ជាក់ពីមូលហេតុរបស់វា។ | លំហាត់<br>បញ្ជីសំណួរ<br>ជ្រើសរើស ចម្លើយ |

# លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់មានប៉ុន្មានជំហាន?**

ក). ២ ជំហាន

ខ). ៣ ជំហាន

គ). ៥ ជំហាន

**២.តើជំហានទី២នៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជាអ្វី?**

ក). ការសិក្សាពីបញ្ហា និងតម្រូវការ

ខ). សមាហរណកម្មថ្នាក់ស្រុក

គ). ការប្រជុំរៀបចំគម្រោង

**៣.តើជំហានទី៣នៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជាអ្វី?**

ក). ការសិក្សាពីបញ្ហា និងតម្រូវការ

ខ). សមាហរណកម្មថ្នាក់ស្រុក

គ). ការប្រជុំរៀបចំគម្រោង

**៤.តើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវធ្វើឡើងនៅជំហានទីប៉ុន្មាន?**

ក). ២ ជំហាន

ខ). ៣ ជំហាន

គ). ១ ជំហាន

**៥. តើអ្វីទៅជាការបញ្ជ្រាបការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់?**

ក). គឺជាការរៀបចំផែនការឃុំ សង្កាត់

ខ). មានន័យថាគម្រោងថ្មីត្រូវបានលើកឡើងដើម្បីបង្កើននូវភាពធន់ចំពោះការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

គ). រៀបចំ និងចាត់ចំណាត់ថ្នាក់គម្រោងដែលមានភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ

# ចម្លើយសម្រាប់លំហាត់ បញ្ជីសំណួរជ្រើសរើសចម្លើយ

សូមជ្រើសរើស និងគូសរង្វង់ចម្លើយមួយដែលត្រឹមត្រូវបំផុតក្នុងចំណោមចម្លើយជាច្រើននៃសំណួរខាងក្រោម ៖

**១.តើការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់មានប៉ុន្មានជំហាន?**

ក). ២ ជំហាន

ខ). ៣ ជំហាន

✓ គ). ៥ ជំហាន

**២.តើជំហានទី២នៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជាអ្វី?**

ក). ការសិក្សាពីបញ្ហា និងតម្រូវការ

ខ). សមាហរណកម្មថ្នាក់ស្រុក

✓ គ). ការប្រជុំរៀបចំគម្រោង

**៣.តើជំហានទី៣នៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជាអ្វី?**

ក). ការសិក្សាពីបញ្ហា និងតម្រូវការ

✓ ខ). សមាហរណកម្មថ្នាក់ស្រុក

គ). ការប្រជុំរៀបចំគម្រោង

**៤.តើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវធ្វើឡើងនៅជំហានទីប៉ុន្មាន?**

ក). ២ ជំហាន

ខ). ៣ ជំហាន

✓ គ). ១ ជំហាន

**៥. តើអ្វីទៅជាកាបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់?**

ក). គឺជាការរៀបចំផែនការឃុំ សង្កាត់

✓ ខ). មានន័យថាគម្រោងថ្មីត្រូវបានលើកឡើងដើម្បីបង្កើននូវភាពធន់ចំពោះការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

គ). រៀបចំ និងចាត់ចំណាត់ថ្នាក់គម្រោងដែលមានភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ

# ប្លង់មេរៀន ៦.ការសន្និដ្ឋានបញ្ចប់វគ្គបណ្តុះបណ្តាល

| | |
|---|---|
| **គោលបំណង** | នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងបាន ៖<br>▪ រំលឹកខ្លឹមសារមេរៀនសំខាន់ៗ ទាំងជំពូកទាំង៥<br>▪ វាយតម្លៃបញ្ចប់វគ្គបណ្តុះបណ្តាល |
| **ខ្លឹមសារសំខាន់** | ▪ ចំណុចសំខាន់ៗនៃគ្រប់ជំពូក |
| **រយៈពេល** | ▪ ៧០នាទី |
| **សំភារៈ** | ▪ បញ្ជីសំណួរវាយតម្លៃចំណេះដឹងក្រោយវគ្គ និងទម្រង់វាយតម្លៃបញ្ចប់វគ្គ |
| **វិធីសាស្ត្រ** | ▪ សង្ខេបមេរៀន រំលឹកមេរៀន ការវាយតម្លៃផ្ទាល់ខ្លួន |

**សកម្មភាពសម្របសម្រួលមេរៀន**

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ៥នាទី | **១. ការបង្ហាញសេចក្តីផ្តើម និងគោលបំណង**<br>▪ **សេចក្តីផ្តើម ៖** ផ្នែកនេះនឹងរំលឹកឡើងវិញនូវខ្លឹមសារមេរៀនសំខាន់ៗ និងវាយតម្លៃវគ្គបណ្តុះបណ្តាល<br>▪ **គោលបំណង ៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាច រំលឹកពីខ្លឹមសារមេរៀនសំខាន់ៗ ក្នុងវគ្គបណ្តុះបណ្តាល និងវាយតម្លៃលើវគ្គ | |
| ៥នាទី | **២. ការសង្ខេបចំណុចសំខាន់នៃមេរៀននីមួយៗឡើងវិញ**<br>• អ្នកសម្របសម្រួល បង្ហាញខ្លឹមសារសង្ខេបមេរៀន<br>• អ្នកសម្របសម្រួលឱ្យសិក្ខាកាមសួរ រួចផ្តល់ចម្លើយ ។ | |
| ៣០នាទី | **៣. ការត្រួតពិនិត្យក្រោយវគ្គ**<br>• អ្នកសម្របសម្រួលចែក និងពន្យល់បញ្ជីសំណួរត្រួតពិនិត្យក្រោយវគ្គ រួចឱ្យសិក្ខាកាមធ្វើរៀងៗខ្លួន។ ចប់ការបំពេញកិច្ចការនេះ អ្នកសម្រប សម្រួល ប្រមូលលទ្ធផលកិច្ចការទាំងអស់ សម្រាប់បូកសរុប។ | បញ្ជីសំណួរ វាយតម្លៃចំណេះដឹង ក្រោយវគ្គ |

| | ជំហាន និងវិធីសាស្ត្រ | ធនធាន |
|---|---|---|
| ២០នាទី | **៤. ការវាយតម្លៃបញ្ចប់សិក្ខាសាលា**<br>• អ្នកសម្របសម្រួលចែក និងពន្យល់ទម្រង់វាយតម្លៃបញ្ចប់វគ្គបណ្តុះបណ្តាល រួចឱ្យសិក្ខាកាមធ្វើរៀងៗខ្លួន។ ចប់ការបំពេញកិច្ចការនេះ អ្នកសម្របសម្រួលប្រមូលលទ្ធផលកិច្ចការទាំងអស់។ | ទម្រង់វាយតម្លៃបញ្ចប់វគ្គ |
| ១០នាទី | **៥. សេចក្តីសន្និដ្ឋានបញ្ចប់សិក្ខាសាលា**<br>ប្រធាន ឬតំណាងក្រុមអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលៈ<br>មានមតិចំណាប់អារម្មណ៍ល្អជាមួយសិក្ខាកាម<br>ថ្លែងអំណរគុណដល់សិក្ខាកាម ដែលបានចូលរួម រៀនសូត្រ និងជូនពរឲ្យសិក្ខាកាមអាចយកចំណេះដឹងទៅអនុវត្តនៅតាមមូលដ្ឋានរបស់ខ្លួនបានជោគជ័យ។ | |

# ទម្រង់វាយតម្លៃបញ្ចប់វគ្គបណ្តុះបណ្តាល

១. តើវគ្គនេះ ឆ្លើយតបនឹងគោលបំណងដែលបានកំណត់កម្រិតណា? សូមគូសសញ្ញា ✓ ក្នុងប្រអប់ខាងក្រោម ៖

| ☐ | ☐ | ☐ | ☐ | ☐ |
|---|---|---|---|---|
| មិនឆ្លើយតបសោះ | បានបន្តិចបន្តួច | បានគួរសម | បានច្រើន | ឆ្លើយតបទាំងស្រុង |

២. តើមេរៀន ឬផ្នែកណាដែលសំខាន់បំផុតសម្រាប់អ្នក?

.................................................................................................

.................................................................................................

.................................................................................................

៣. តើមេរៀន ឬផ្នែកណាដែលសំខាន់តិចតួចសម្រាប់អ្នក?

.................................................................................................

.................................................................................................

.................................................................................................

៤. សូមគូសសញ្ញា ✓ នៅក្នុងតារាងខាងក្រោមនូវកម្រិតយល់ដឹងរបស់អ្នកពីវគ្គនេះ ៖

| ផ្នែក | ខ្សោយណាស់ | ខ្សោយ | មធ្យម | ល្អ | ល្អណាស់ |
|---|---|---|---|---|---|
| ប្រធានបទ/ខ្លឹមសារមេរៀន | | | | | |
| ដំណើរការ/វិធីសាស្ត្រ/ឧបករណ៍ | | | | | |
| អ្នកសម្របសម្រួល | | | | | |
| ទីកន្លែង | | | | | |

៥. សូមបង្ហាញពីការរីកចម្រើននៃចំណេះដឹងរបស់អ្នក ដោយគូសរង្វង់មូលលើលេខនៃខ្នាត ដូចខាងក្រោម ៖

⚠ បញ្ជាក់ ៖ ១ = គ្មានការរីកចម្រើនសោះ  ១០ = រីកចម្រើនទាំងស្រុង

ក). មុនពេលចូលវគ្គ  ១ |—|—|—|—|—|—|—|—|—|→

ខ). ក្រោយពីបញ្ចប់វគ្គ  ១ |—|—|—|—|—|—|—|—|—|→

៦. តើចំណុចណាខ្លះ ដែលអ្នកពេញចិត្តបំផុតក្នុងវគ្គបណ្តុះបណ្តាលនេះ?

.................................................................................................

.................................................................................................

.................................................................................................

៧. សំណូមពរ និងយោបល់ផ្សេងៗ

.................................................................................................

.................................................................................................

.................................................................................................

# ឧបសម្ព័ន្ធ១៖ ឯកសារយោង

គ.ជ.អ.ប (២០១៤) សៀវភៅណែនាំបច្ចេកទេស ស្តីពី ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ ឃុំ សង្កាត់

គ.ជ.អ.ប (២០១៤) ប្លង់មេរៀនការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ឃុំបូរីជលសារ (២០១៣-២០១៧) ផែនការអភិវឌ្ឍឃុំ ៥ឆ្នាំ

ក្រសួងបរិស្ថាន និង អង្គការផ្លែនអន្តរជាតិកម្ពុជា (២០១៣) ស្វែងយល់ពីការប្រែប្រួលអាកាសធាតុ៖ ឯកសារជំនួយស្មារតីសម្រាប់សាលាមធ្យមសិក្សា

JCCI, Forum Syd DCA/CA, and Cord, Plan, World Vision, & Caritas Cambodia សៀវភៅណែនាំអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖ សន្ទានុក្រម និងពាក្យបំព្រួញ

Robert W. Solar(2014), Building Climate Resilience: A Training Manual for Community Based Climate Change Adaptation, Partner Report Series No 14, Regional Climate Change Adaptation Knowledge Platform for Asia

UNDP SGP (២០១៤) ឯកសារមគ្គុទេសក៍សម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន៖ ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ

# ឧបសម្ព័ន្ធ២៖ សទ្ទានុក្រម

**ការបន្សាំ ៖** ការសម្របនៃប្រព័ន្ធធម្មជាតិ ឬមនុស្ស ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ជាក់ស្តែង ឬរំពឹងទុក នៃការប្រែប្រួលអាកាសធាតុ។ ការសម្រប / ការបន្សាំនេះ អាចជួយកាត់បន្ថយគ្រោះថ្នាក់ ឬទាញយកឱកាសដើម្បីជាប្រយោជន៍ផងដែរ។

**អាកាសធាតុ ៖** លក្ខខណ្ឌមធ្យមរយៈពេលវែងក្នុងបរិយាកាស ដែលអាចពិពណ៌នាតាមរូបមន្តស្ថិតិ ដូចជា មធ្យមភាគ និងវិសមរូបនៃធាតុផ្សំនានាក្នុងលក្ខខណ្ឌបរិយាកាស។ អាកាសធាតុតំណាងឲ្យលក្ខខណ្ឌបរិយាកាសទូទី ក្នុងរយៈពេលវែងមួយ (៣០ឆ្នាំ ដូចដែលកំណត់ដោយអង្គការឧតុនិយមពិភពលោក)។

**ការប្រែប្រួលអាកាសធាតុ ៖** ការប្រែប្រួលបន្តិចម្តងៗនៃអាកាសធាតុនៅក្នុងរយៈពេលវែង។ ការប្រែប្រួលនេះ រួមមាន ការប្រែប្រួលសីតុណ្ហភាព ខ្យល់ និងទឹកសមុទ្រ របបទឹកភ្លៀង និងខ្យល់ ផ្ទាំងទឹកកកលើសកលលោកជាដើម។ ការប្រែប្រួលទាំងនេះកើតមានតាមធម្មជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធអាកាសធាតុ និងក៏បណ្តាលមកពីសកម្មភាពមនុស្សផងដែរ។

**ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ៖** ការបន្សាំ ត្រូវបានចាត់ទុកថាជាអ្វីដែលយើងធ្វើ ដោយគ្រោងទុក ឬមិនបានគ្រោងទុកនៅក្នុងការសម្របខ្លួនទៅនឹងលក្ខខណ្ឌថ្មី ភាពតានតឹង និងគ្រោះមហន្តរាយធម្មជាតិ។ ការបន្សាំទាំងនេះជំរុញឲ្យមានការបង្កើនភាពធន់របស់ប្រជាជន ទៅនឹងការប្រែប្រួលអាកាសធាតុ។

**គ្រោះមហន្តរាយ ៖** សំដៅលើការរំខានធ្ងន់ធ្ងរនៅក្នុងសហគមន៍ណាមួយ ដែលបង្កឲ្យមានការបាត់បង់ធនធានមនុស្ស សម្ភារៈសេដ្ឋកិច្ច ឬបរិស្ថាន ក្នុងកម្រិតដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់សហគមន៍រងគ្រោះ ក្នុងការទប់ទល់ដោយប្រើប្រាស់ធនធានរបស់ខ្លួន។ ជារឿយៗគ្រោះមហន្តរាយ បណ្តាលមកពីកត្តាផ្សំនានាដូចជា ១) ជាតំបន់ដែលងាយរងគ្រោះទៅនឹងគ្រោះថ្នាក់ ២) កម្រិតធ្ងន់ធ្ងរនៃព្រឹត្តិការណ៍ធាតុអាកាស និង ៣) សមត្ថភាព ឬវិធានការមិនគ្រប់គ្រាន់ក្នុងការកាត់បន្ថយ ឬទប់ទល់នឹងផលវិបាកនៃព្រឹត្តិការណ៍ធាតុអាកាសកំណាច។

**ហានិភ័យនៃគ្រោះមហន្តរាយ ៖** សក្តានុពលនៃគ្រោះមហន្តរាយ ដែលអាចកើតមានឡើងនៅក្នុងសហគមន៍ ឬសង្គមមួយទៅអនាគត។ តាំងពីមុនមក គ្រោះមហន្តរាយត្រូវបានទស្សន៍ទាយសម្រាប់រយៈពេលវែងនៅក្នុងតំបន់ភាគច្រើន។ នៅក្នុងតំបន់ខ្លះលក្ខខណ្ឌហានិភ័យនៅតែបន្តកើតមានជាប់ជាប្រចាំ។ តាមរយៈចំណេះដឹងអំពីមុខសញ្ញាគ្រោះថ្នាក់ដែលមានជាទូទៅ គេអាចប៉ាន់ប្រមាណ និងដោះស្រាយហានិភ័យនៃគ្រោះមហន្តរាយ។

**ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ៖** ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយមានគោលបំណងបញ្ចៀស ឬកាត់បន្ថយផលវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់នានាតាមរយៈសកម្មភាព និងវិធានការទប់ស្កាត់ ការកាត់បន្ថយ និងការត្រៀមបង្ការ។ សកម្មភាពនេះអាចអនុវត្តជាលក្ខណៈបុគ្គល និងតាមរយៈអង្គការ ឬរដ្ឋាភិបាលទាំងនៅថ្នាក់មូលដ្ឋាន និងជាតិ។ ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ទាក់ទងនឹងវិស័យជាច្រើនដែលរួមមាន៖ ការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងការប្រើប្រាស់ដី ការអភិរក្សធនធានសំខាន់ៗ ប្រព័ន្ធប្រកាសអាសន្ន និងការឆ្លើយតបជាបន្ទាន់។
ប្រព័ន្ធអេកូឡូស៊ី ៖ សហគមន៍ជីវសាស្ត្រនៃសារពាង្គកាយ ដែលមានអន្តរកម្មរវាងគ្នា និងបរិស្ថានរូបវន្តនៃសារពាង្គកាយទាំងនោះ។

**ឧស្ម័នផ្ទះកញ្ចក់ ៖** ឧស្ម័នដែលបង្កឲ្យមានការឡើងកំដៅផែនដី និងការប្រែប្រួលអាកាសធាតុ។ ឧស្ម័នផ្ទះកញ្ចក់ចម្បងៗមានដូចជា ឧស្ម័នកាបូនិក (CO2) មេតាន (CH4) ឌីអាសូតម៉ូណូអុកស៊ីត (N2O)។ ឧស្ម័នផ្ទះកញ្ចក់បន្ទាប់បន្សំដែលមានឥទ្ធិពលខ្លាំងមានដូចជា អ៊ីដ្រូហ្លុយអ័រ៉ូកាបូន (PFCs) និងស៊ុលផួរអិចសាហ្លូរីត (SF6)។

**ចំហាយទឹក** (H2O) ជាឧស្ម័នផ្ទះកញ្ចក់មួយប្រភេទដែលកើតឡើងដោយសារធម្មជាតិតាមរយៈវដ្តទឹក។

**កាបូនិក** (CO2) កើតឡើងដោយសារការដុតឥន្ធនៈផូស៊ីល (ធ្យូងថ្ម ប្រេង និងឧស្ម័ន) និងការកាប់បំផ្លាញព្រៃឈើ។

**ឧស្ម័នមេតាន** (CH4) មានប្រភពចំបងមកពីការពុកផុយនៃអង្គធាតុសរីរាង្គផ្សេងៗ ដែលកង្វះអុកស៊ីសែន ការធ្វើស្រែ ការចិញ្ចឹមសត្វ សំណល់រឹង រាវ ។ល។

**ឌីអាសូតម៉ូណូអុកស៊ីត** (N2O) មានប្រភពចំបងមកពីការធ្វើកសិកម្ម ការប្រើជីគីមី។

**អ៊ីដ្រូហ្វុយអរ៉ូកាបូន** (HFCs) មានប្រភពពីដំណើរការឧស្សាហកម្ម និងការប្រើប្រាស់ដូចជា ការប្រើម៉ាស៊ីនត្រជាក់ ទូទឹកកកថ្នាំបាញ់ និងផលិតផលនៃសារធាតុរំលាយជាដើម។

**ពែរហ្វុយអរ៉ូកាបូន** (PFCs) មានប្រភពពីដំណើរការឧស្សាហកម្ម ដូចជាការផលិតអាលុយមីញ៉ូម។

**ស៊ុលផួរអិចសាហ្វ្លរីត**(SF6) មានប្រភពពីដំណើការឧស្សាហ៍កម្មដូចជាការផលិតម៉ាញេស្យូម។

**ធាតុអាកាស ៖** ស្ថានភាពបរិយាកាសក្នុងពេល និងទីកន្លែងណាមួយ ដែលអាចរាស់បាន ពាក់ព័ន្ធនឹងការអថេរនានា ដែលរួមមានសីតុណ្ហភាព កំណកអាកាស វត្តមានពពក សំណើម សម្ពាធអាកាស និងខ្យល់។ ធាតុអាកាស អាចប្រែប្រួលច្រើនដងក្នុងមួយថ្ងៃ និងពីមួយថ្ងៃទៅមួយថ្ងៃ។

# ឧបសម្ព័ន្ធ៣៖ លំហាត់ករណីសិក្សា

### លំហាត់ករណីសិក្សាមេរៀនទី២៖ គូសផែនទីនៃគ្រោះមហន្តរាយ ឃុំបូរីជលសារ
Disaster Risk Mapping

ក្រុមពិភាក្សាសាកល្បង គូសផែនទីហានិភ័យនៃគ្រោះមហន្តរាយរបស់ឃុំណាមួយ ឬ របស់ឃុំបូរីជលសារ ដែលមានព័ត៌មាន និងផែនទីរដ្ឋបាលដូចខាងក្រោម៖

ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ដែលមានព័ត៌មានសំខាន់ៗខាងក្រោម៖

| | |
|---|---|
| ផ្ទៃដីឃុំ | ៦,៦០០ ហិចតា |
| ចំនួនភូមិ | ៧ ភូមិ |
| ស្ត្រីចូលរួមក្នុងក្រុមប្រឹក្សាឃុំ និងអ្នកដឹកនាំភូមិ | ៨ នាក់ |
| ចំនួនប្រជាជនសរុប | ៣,៩៣៥ នាក់ |
| ចំនួនស្ត្រីសរុប | ១,៩៣៣ នាក់ |
| ភាគរយកំណើនប្រជាជនប្រចាំឆ្នាំ | % |
| ចំនួនគ្រួសារសរុប | ៨០៩ គ្រួសារ |
| ភាគរយស្ត្រីជាមេគ្រួសារ | % |
| ភាគរយគ្រួសារមានមុខរបរ | % |
| ប្រវែងផ្លូវដឹកជញ្ជូនសរុប | ១៥,៩៥០ ម |
| ប្រព័ន្ធស្រោចស្រព (ប្រវែងប្រឡាយសរុប) | ម |
| ភាគរយកុមារអាយុ ៦ដល់១៨ឆ្នាំមិនបានចូលរៀន | % |
| ភាគរយអ្នកមិនចេះអក្សរពីអាយុ ១៥-៦០ឆ្នាំ | % |
| ភាគរយស្ត្រីមិនចេះអក្សរពីអាយុ ១៥-៦០ឆ្នាំ | % |
| ចំនួនស្ត្រីសម្រាលកូនសរុប | នាក់ |
| ភាគរយស្ត្រីសម្រាលកូនដោយឆ្មបបុរាណ | ០% |
| ភាគរយគ្រួសារប្រើប្រាស់ទឹកស្អាត ទឹកម៉ាស៊ីន អណ្តូងស្នប់ | % |
| ភាគរយគ្រួសារមានបង្គន់អនាម័យ | % |

**ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម**

អាស្រ័យដោយមូលដ្ឋានរបស់ឃុំបូរីជលសារ ជាដែនដីសណ្តទទួលពីរបបធារទឹកទន្លេមេគង្គជារៀងរាល់ឆ្នាំបានខណ្ឌចែកភូមិសាស្ត្រជាពីរគឺ ៦ខែទឹកលិច និង៦ខែគោក ដែលមានចំណុចចំណតបេនស្ថិតក្នុងភូមិអំពិល ឃុំបូរីជលសារ ជាទីតាំងប្រសព្វស្នូលនៃភូមិសាស្ត្រទាំងពីរ។ ទន្ទឹមជាមួយនឹងស្ថានភាពខាងលើ ស្ទើររៀងរាល់ឆ្នាំនៅក្នុងមូលដ្ឋានរបស់ឃុំទាំងមូលតែងបានកើតឡើងនិងជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិពីរផងដែរក្នុងពេលតែមួយគឺ គ្រោះរាំងស្ងួត និងទឹកជំនន់នារដូវវស្សា ហើយបញ្ហានេះបានជះឥទ្ធិពល និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភោគផលដំណាំរបស់ប្រជាកសិករ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរបស់មូលដ្ឋាន។ ឃុំបូរីជលសារ នៅពុំទាន់មានប្រព័ន្ធគមនាគមន៍ផ្លូវគោកសម្រាប់ទំនាក់ទំនងឆ្លងកាត់ពីមូលដ្ឋានមួយទៅមូលដ្ឋានមួយទៀតនូវឡើយដែលបញ្ហាទាំងនេះបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់ជាអាទិភាពចំពោះមុខក្នុងគោលដៅកៀរគរប្រភពធនធាន ដើម្បីដោះស្រាយរួមចំណែកកាត់បន្ថយភាពឃ្លាតឆ្ងាយពីគ្នារវាងទីប្រជុំជន និង

មូលដ្ឋានដាច់ស្រយ៉ាល ។

**គ្រោះធម្មជាតិ**

ទឹកជំនន់ និងគ្រោះរាំងស្ងួតភាគច្រើនប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋនៅឃុំផលសារ ហាក់មានភាពសាំកុ្នងការរស់នៅជាមួយនឹងទឹកជំនន់ ប៉ុន្តែមានការប៉ះពាល់រងគ្រោះដល់ជីវិតច្រើនកើតមាន ព្រោះសណ្ឋានដីទាប។ ចំនួនអ្នកស្លាប់ ឆ្នាំ២០១៣ បណ្តាលមកពីគ្រោះទឹកជំនន់មាន៦នាក់ ស្រីចំនួន២នាក់។




**ប្រភពៈ ឃុំបូរីផលសារ (២០១៣-២០១៧:៤) ផែនការអភិវឌ្ឍ៥ឆ្នាំ**

ចំណាំ៖ អាចប្រើនិមិត្តសញ្ញាក្នុងសៀវភៅ C/S PIM (2009) ឬ ប្រើនិមិត្តសញ្ញា និងពណ៌ ខាងក្រោមពេលគូសផែនទីហានិភ័យគ្រោះមហន្តរាយ[១] ៖

| លក្ខណៈពិសេស | ការបង្ហាញនៅលើផែនទីហានិភ័យគ្រោះមហន្តរាយ | សម្គាល់ |
|---|---|---|
| ព្រំប្រទល់រដ្ឋបាល |  | |
| ផ្លូវ ស្ពាន |  | |
| បឹង ទន្លេ |  | |
| របនាសម្ព័ន្ធធារាសាស្ត្រ ទំនប់ទឹកអាងស្តុកទឹក វារីអគ្គីសនី |  | |
| អណ្តូងទឹក និងស្រះ |  | |
| អគារសាធារណៈ |  | សូមពន្យល់/ពណ៌នាអំពីកន្លែងនីមួយដែលដាក់លើផែនទី |
| មាស៊ីនភ្លើងសាធារណៈ ឬប្រព័ន្ធពន្លឺព្រះអាទិត្យ |  | សូមពន្យល់/ពណ៌នាអំពីកន្លែងនីមួយដែលដាក់លើផែនទី |
| បូជនីយដ្ឋាន |  | សូមពន្យល់/ពណ៌នាអំពីកន្លែងនីមួយដែលដាក់លើផែនទី |
| កន្លែងចាក់សម្រាម និងតំបន់ដែលបោះសំរាម |  | សូមពន្យល់/ពណ៌នាអំពីកន្លែងនីមួយដែលដាក់លើផែនទី |
| តំបន់ព្រៃ និងតំបន់អតិរក្ស |  | សូមពន្យល់/ពណ៌នាអំពីកន្លែងនីមួយដែលដាក់លើផែនទី |
| តំបន់ដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយទាក់ទងនឹង អាកាសធាតុ |  | ព័ត៌មានបន្ថែមគួរមាន បញ្ជាក់នៅតាមតំបន់នីមួយៗ<br>- ប្រភេទនៃគ្រោះមហន្តរាយ<br>- ភាពញឹកញាប់<br>- ផលប៉ះពាល់ |

- ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងម្នាក់ដើម្បីធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សាក្រុម
- ពេលវេលាសម្រាប់ការពិភាក្សា និងអនុវត្តសាកល្បងមានចំនួន ៨០នាទី
- ក្រុមនីមួយៗមានពេល១០នាទីសម្រាប់បង្ហាញ

[១] ឯកសារយោង: គ.ជ.អ.ប (២០១៨) ឧបករណ៍គូសផែនទីគ្រោះមហន្តរាយ

# លំហាត់ករណីសិក្សាមេរៀនទី៣៖ វិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ និងទម្រង់ H ឃុំបូរីជលសារ

**ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម**

ឃុំបូរីជលសារ ជាដែនដីសណ្តទទួលពីរបបធារទឹកទន្លេមេគង្គជារៀងរាល់ឆ្នាំ បានខណ្ឌចែកតួមិសាស្ត្រជាពីរគឺ ៦ខែទឹកលិច និង៦ខែគោក ដែលមានចំណុចចំណាតបេនស្ថិតក្នុងតួមិអំពិល ឃុំបូរីជលសារជាទីតាំងប្រសព្វស្នូលនៃតួមិសាស្ត្រទាំងពីរ។ ទន្ទឹមជាមួយនឹងស្ថានភាពខាងលើ ស្ទើររៀងរាល់ឆ្នាំនៅក្នុងមូលដ្ឋានរបស់ឃុំទាំងមូលតែងបានកើតឡើង និងជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិពីរផងដែរក្នុងពេលតែមួយគឺ គ្រោះរាំងស្ងួត និងទឹកជំនន់នារដូវវស្សា ហើយបញ្ហានេះបានជះឥទ្ធិពល និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើគោគផលដំណាំរបស់ប្រជាកសិករ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរបស់មូលដ្ឋាន។ ឃុំបូរីជលសារ នៅពុំទាន់មានប្រព័ន្ធគមនាគមន៍ផ្លូវគោកសម្រាប់ទំនាក់ទំនងឆ្លងកាត់ពីមូលដ្ឋានមួយទៅមូលដ្ឋានមួយទៀតនូវឡើយ ដែលបញ្ហាទាំងនេះបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់ជាអាទិភាពចំពោះមុខក្នុងគោលដៅកៀរគរប្រតពធនធាន ដើម្បីដោះស្រាយរួមចំណែកកាត់បន្ថយភាពឃ្លាតឆ្ងាយពីគ្នារវាងទីប្រជុំជន និងមូលដ្ឋានដាច់ស្រយ៉ាល ។

**គ្រោះធម្មជាតិ**

ទឹកជំនន់ និងគ្រោះរាំងស្ងួតភាគច្រើនប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋនៅឃុំជលសារហាក់មានភាពសាំក្នុងការរស់នៅជាមួយនឹងទឹកជំនន់ ប៉ុន្តែមានការប៉ះពាល់រងគ្រោះដល់ជីវិតច្រើនកើតមាន ព្រោះសណ្ឋានដីទាប។ ចំនួនអ្នកស្លាប់ ឆ្នាំ២០១៣ បណ្តាលមកពីគ្រោះទឹកជំនន់មាន៦នាក់ ស្រីចំនួន២នាក់។

ក្រុមពិភាក្សា ចងក្រងព័ត៌មានស្តីពីគ្រោះមហន្តរាយ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់ឃុំបូរីជលសារ ឬឃុំណាមួយរបស់ខ្លួន។ សំណួរសំរាប់ការពិភាក្សាពីការវិភាគនិន្នាការ និងទម្រង់ H ទាំង៤ មានដូចខាងក្រោម៖

**ក.ផ្នែកវិភាគនិន្នាការ**

១. ចូរវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុរបស់(ឃុំណាមួយ ឬ) ឃុំបូរីជលសារ។ ដាក់ពិន្ទុពី ១ ទៅ ៥ (ដាក់ពិន្ទុ១ បើងាយរងគ្រោះតិចតួច និងដាក់ពិន្ទុ៥ បើងាយរងគ្រោះខ្លាំង)ក្នុងតារាងវិភាគនិន្នាការ។

**ខ.ផ្នែកវាយតម្លៃការកាត់បន្ថយភាពរងគ្រោះពីការប្រែប្រួលអាកាសធាតុ ( ទម្រង់ Hទាំង៤ )**

២. តើអ្វីជាស្ថានភាពនៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន?

៣. តើមានអ្វីនឹងកើតឡើងប្រសិនបើស្ថានភាពកាន់តែអាក្រក់ជាងមុនទ្វេដង ឬកាន់តែយ៉ាប់យឺនទៅ?

៤. តើកត្តាអ្វីដែលជាឧបសគ្គរាំងអ្នកមិនឲ្យបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នាពេលបច្ចុប្បន្ន?

៥. តើសកម្មភាពអ្វីខ្លះដែលអ្នកគិតថា អាចជួយកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកនិងសហគមន៍?

**ចំណាំ៖**

- ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងម្នាក់ដើម្បីធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សាក្រុម
- ពេលវេលាសម្រាប់ការពិភាក្សា និងអនុវត្តសាកល្បងមានចំនួន ៤០នាទី
- ក្រុមនីមួយៗមានពេល១០នាទីសម្រាប់បង្ហាញ

# លំហាត់ករណីសិក្សាមេរៀនទី៤៖ ឧបករណ៍ ចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃកម្មវិធី Disaster Ranking

ដោយផ្អែកតាមការសិក្សាអំពីបញ្ហា និងតម្រូវការឃើញថាប្រជាពលរដ្ឋ និងអាជ្ញាធរក្នុងឃុំបូរីដែលសារក្នុងករណីសិក្សាទី២ កំពុងជួបប្រទះបញ្ហាពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ជាច្រើនដែលតម្រូវឲ្យមានការជួយអន្តរាគមន៍ដោះស្រាយ។ បញ្ហាទាំងនោះរួមមានដូចជា៖

- ទឹកជំនន់
- គ្រោះរាំងស្ងួត
- ព្យុះផ្គរ/រន្ទះ
- គ្រុនចាញ់

ដូច្នេះ ក្រុមពិភាក្សាត្រូវជួយក្នុងការចំណាត់ថ្នាក់ភាពងាយរងគ្រោះបញ្ហាពីបំរែបំរួលអាកាសធាតុ និងគ្រោះមហន្តរាយខាងលើ ដើម្បីស្វែងរកថាតើគួរដោះស្រាយបញ្ហាណាមុនគេ?

ចំណាំ៖

- ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងម្នាក់ដើម្បីធ្វើបទបង្ហាញពីលទ្ធផលនៃកិច្ចពិភាក្សាក្រុម
- ពេលវេលាសម្រាប់ការពិភាក្សា និងអនុវត្តសាកល្បងមានចំនួន ៥០នាទី
- ក្រុមនីមួយៗមានពេល១០នាទីសម្រាប់បង្ហាញ

ផលិតដោយ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន គ.ជ.អ.ប